00882169

E1/162.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jan-2013, 14:06
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៦នាទី**

**សវនាការលើកទី១៤៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្សី

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ឃីត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ

*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក សំ សុគង់

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតាមកាលវិភាគដែលបានគ្រោងទុក ហើយអង្គជំនុំជម្រះបានជម្រាបជូនភាគីកាលពីម្សិលមិញថា នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការលើឯកសារ ដែលភាគីដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមានលើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ រីឯជនជាប់ចោទ នួន ជា និង ខៀវ សំផន អវត្តមានដោយមូលហេតុសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ប៉ុន្តែជនជាប់ចោទទាំងពីរបានដាក់នូវលិខិតលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការលើឯកសារនេះ។ ឯកសារលេខ E258/2 និង E223/4។ សូមអរគុណ។

[០៩:០៨:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញលើការអវត្តមានជនជាប់ចោទ នួន ជា ជាមួយនិងលោក ខៀវ សំផន ដែលគាត់មានបញ្ហាសុខភាព គាត់មានជំងឺត្រូវទទួលព្យាបាលនៅឯមន្ទីរពេទ្យ ហើយគាត់បានលះបង់សិទ្ធិក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើឯកសារ។ ដូច្នេះនៅក្នុងកិច្ចដំណើរការសវនាការនេះ យើងប្រព្រឹត្តទៅជាធម្មតា ដោយគាត់បានលះបង់សិទ្ធិយ៉ាងច្បាស់លាស់ដោយស្ថានភាពសុខភាព និងបញ្ហាស្មារតីគាត់សមស្រប។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការបង្ហាញឯកសារ

គន្លឹះនានា ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនៃរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ។

សូមអញ្ជើញ!

[០៩:០៩:៤៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់គ្នា។ នៅពេលនេះខ្ញុំសូមឲ្យអស់លោក លោកស្រី ពិនិត្យមើលឯកសារមួយចំនួនចាប់ពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ១៩៧៦ -- ចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ១៩៧៦ ដែលវាជារបាយការណ៍កិច្ចប្រជុំរបស់ សុន សេន ជាមួយនឹងលេខា។ នេះជារបាយការណ៍របស់កងពល និងជាលិខិតទាក់ទងលើបញ្ហាគោលនយោបាយ និងមាគ៌ាយោធាផងដែរ។ ឯកសារដំបូងគឺ E3/814 គឺកំណត់ហេតុកិច្ចប្រជុំនៃគណៈកម្មាធិការកងពលចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦។ កិច្ចប្រជុំនោះ គឺពាក់ព័ន្ធទៅនឹងផលិតកម្មកសិកម្មហើយបានកត់ត្រាទុកនូវការទំនាក់ទំនងផែនការ និងមាគ៌ារបស់យោធាទៅដល់កងពលរបស់បក្ស។ ចំណុចទី៣ នៃកិច្ចប្រជុំនោះ គឺដក -- ខ្ញុំសូមដកស្រង់ថា "ការពិភាក្សាមួយចំនួនពាក់ព័ន្ធទៅនឹងការវាយសម្រុកដើម្បីបានបីតោនក្នុងមួយហិកតា ហើយនិងយុទ្ធសាស្ត្រផ្គត់ផ្គង់ខ្លួនឯងសម្រាប់អង្គការ"។ នៅក្នុងរបាយការណ៍របស់ បង៨៩ ត្រង់ទំព័រទី២ ត្រង់កថាខណ្ឌ២(ខ) គឺពាក់ព័ន្ធនឹងការកសាងជាតិ សុន សេន បានណែនាំទៅដល់កងពលដូចតទៅ សូមដកស្រង់សម្ដី "ការងាររបស់យើងគឺបង្កើនផលិតផលទៅ ដល់បីតោនក្នុងមួយហិកតា និងលើកប្រព័ន្ធភ្លឺឲ្យបាន ៣០ភាគរយ ចលនាលោតផ្លោះខ្លាំងនៅជនបទហើយ។ ចលនាធ្វើព្រែកជីក ចលនាធ្វើប្រឡាយ ចលនាលើកប្រព័ន្ធភ្លឺខ្លាំងក្លាណាស់"។ សូមបញ្ចប់ការដកស្រង់សម្ដី។

[០៩:១២:២៣]

ផែនការលម្អិតចំពោះផលិតផលកសិកម្មបានលើកឡើងដោយ សុន សេន ទៅដល់លេខាកងពល ហើយដែលពេលនោះលើកនៅក្នុងកិច្ចប្រជុំថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ឯកសារលេខ E3/797 ដែលនៅក្នុងនោះនិយាយអំពីផ្ទៃដីដែលត្រូវដាំដុះ ហើយនិងបញ្ហាទុន៤៨ម៉ឺនដុល្លារ នៅក្នុងឆ្នាំ១៩៧៨។ ឯកសារមួយទៀតគឺឯកសារ E3/790 ជាសេចក្ដីសម្រេចរបស់ -- សេចក្ដីសម្រេចចិត្តរបស់សន្និបាតគណៈកម្មាធិការបក្សគ្រប់កងពលនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦។ នេះគឺ ជាសន្និបាតលើកទី២ របស់គណៈកម្មាធិការ ឯកសារគឺបានយោងថាវាបានប្រជុំឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៦។ ឯកសារនេះគឺលេច

ចេញមកពីសន្និបាតខែកក្កដា ឆ្នាំ១៩៧៦ ហើយឯកសារនេះបែងចែកជា ផ្នែករៀបរាប់លម្អិតអំពីភារកិច្ចរបស់កងទ័ពបដិវត្តន៍កម្ពុជា។ ទី១ គឺនិយាយអំពីភារៈបន្ត -- កិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម។ ចំណុចទី២ នៅក្នុងឯកសារនេះ គឺនិយាយអំពីភារកិច្ចក្នុងការការពារប្រទេស និងការកសាងទ័ពបដិវត្តន៍ឲ្យទៅជាឧបករណ៍ផ្ដាច់ការ វណ្ណៈអធនរបស់បក្សដាច់ខាត។ ចំណុចទី៣ មានចំណងជើងថា ភារកិច្ចវាយសម្រុកកសាងសង្គមនិយម ពិសេស វាយសម្រុកបីតោនមួយហិកតាឲ្យបាន។ ចំណុចទី៤ និយាយអំពីភារកិច្ចកសាងបក្ស និងទី៥ និយាយអំពីភារកិច្ចទប់ទល់ និងកម្ទាត់ សង្គ្រាមចារកម្ម។

[០៩:១៥:០០]

នៅក្នុងផ្នែកទី២ នៃឯកសារនេះដែលនិយាយអំពីភារកិច្ចកសាងប្រទេស ចំណុចទី២ គឺត្រង់ទំព័រខ្មែរលេខ 00441999 រហូតទៅដល់ 00442000, អង់គ្លេសមានលេខ ERN 00714788 រហូតទៅដល់ 714789, បារាំងមានលេខ 00752245។ ផ្នែកនៃឯកសារត្រង់ចំណុចនេះគឺនិយាយអំពីវិធានការទាំងប្រាំដែលបានសម្រេចឡើង។ ចំណុចទី១ ខ្ញុំសូមដកស្រង់សម្ដី "ត្រូវចាប់អារម្មណ៍ឲ្យខ្លាំងអំពីសកម្មភាពស៊ីរូងផ្ទៃក្នុងកងទ័ពបដិវត្តន៍យើង និងនៅក្នុងជួរបដិវត្តន៍" បញ្ចប់ការដកស្រង់សម្ដី។

[០៩:១៦:០១]

វិធានការទី៤ ដែលបានសរសេរនៅក្នុងនោះគឺថា "ត្រូវក្ដោបឲ្យជាប់នូវប្រវត្តិរូបរបស់យុទ្ធជនជាពិសេសត្រូវពិនិត្យដល់ភូមិកំណើត ហើយសម្រិតសម្រាំងសមាសភាពអន្តរាយ សមាសភាពប្រឆាំងបដិវត្តន៍ឲ្យអស់ពីក្នុងជួរបដិវត្តន៍យើងជាដាច់ខាត ដើម្បីធ្វើឲ្យកងទ័ពទៅជាឧបករណ៍វណ្ណៈអធនដ៏ស្មោះត្រង់ចំពោះបក្ស ចំពោះមាគ៌ាបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយម និងការការពារប្រទេសរបស់បក្សដាច់ខាត" បញ្ចប់ការដកស្រង់សម្ដី។

ចំណុចទី៤ នៃសេចក្ដីសម្រេចចុះខែកក្កដា ឆ្នាំ១៩៧៦ នៅក្នុងសន្និបាតនេះ គឺលើកឡើងនៅក្នុងកថាខណ្ឌមួយនិយាយអំពីខាងនយោបាយសតិអារម្មណ៍។ ខ្មែរ ERN ត្រង់លេខ 00442011, អង់គ្លេសមានលេខ ERN 00714793, បារាំងមានលេខ 00752251 ដែលមានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ក្នុង៣ខែខាងមុខនេះ ត្រូវអប់រំលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឲ្យបានទូទៅនៅក្នុងបក្ស និងក្នុងអង្គការយុវកក"។ ដកស្រង់ចំណុចខ្លះ "ត្រូវអប់រំសេចក្ដីសម្រេចចិត្តសន្និបាតកងពលលើកទី២នេះឲ្យបានជ្រួតជ្រាបនៅក្នុងបក្ស ក្នុងអង្គការយុវកក និងក្នុងយុទ្ធជន យុទ្ធនារីនៃកងទ័ពបដិវត្តន៍ទាំងមូល" បញ្ចប់ដកស្រង់សម្ដី។

ពាក់ព័ន្ធទៅនឹងប្រវត្តិរូប ឯកសារនេះគឺបានណែនាំបន្ថែមទៀតនៅក្នុងចំណុច២(ក) ចំណុច២(ក)(២)នៃផ្នែកទី៤នេះ "ត្រូវក្ដោបឲ្យជាប់អំពីប្រវត្តិរូបរបស់បក្សដោយចាត់តាំងបុគ្គលមួយចំនួនធ្វើការតាមដានប្រវត្តិរូបនៅតាមមូលដ្ឋាន" បញ្ចប់ការដកស្រង់សម្ដី។

[០៩:១៨:៣៣]

ចំណុចដកស្រង់ចុងក្រោយនៅក្នុងឯកសារនេះត្រង់កថាខណ្ឌ២(ង)(២) នៃចំណុច៤ ខ្មែរត្រង់លេខ 00442014, អង់គ្លេសមានលេខ 00714795, បារាំងមានលេខ 00752253 ត្រង់កថាខណ្ឌនេះសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ចាំបាច់ត្រូវការចាត់តាំងរៀនសូត្រឯកសាររបស់បក្ស១ខែម្ដង" បញ្ចប់ការដកស្រង់សម្ដី។ ចំណុចយោងជាក់លាក់គឺយោងទៅលើឯកសារចេញមកពីទស្សនាវដ្ដីទង់បដិវត្តឬក៏ទស្សនាវដ្ដីយុវជនបដិវត្ត។

លោកប្រធានជាទីគោរព! សេចក្ដីសម្រេចចុះខែកក្កដា ឆ្នាំ១៩៧៦ របស់សន្និបាតរបស់គណៈកម្មាធិការកងពលគឺឃើញមានយោងនៅក្នុងឯកសារផ្សេងមួយទៀត ដែលខ្ញុំសូមបង្ហាញគឺឯកសារលេខ E3/795។ ពាក់ព័ន្ធទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំរបស់លេខា និងអនុលេខានៃកងវរសេនាតូច ប្រជុំនៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ នៅក្នុងកិច្ចប្រជុំនេះគឺថាមានកងពលនីមួយៗ និងវរសេនាធំនីមួយៗបានរាយការណ៍ទៅបង សុន សេន និយាយអំពីវគ្គអប់រំ ដែលបានណែនាំកម្មាភិបាលអំពីលក្ខន្តិកៈ ហើយនៅក្នុងនោះគឺរៀបរាប់អំពីសន្និបាតដែលបានលើក -- ដែលបានរៀបចំប្រជុំមួយខែមុន។

[០៩:២០:៣៧]

នៅក្នុងចំណុចទី៣(១) នៅក្នុងសេចក្ដីបញ្ចប់សុន្ទរកថា សុន សេន បានលើកឡើងអំពីសារៈសំខាន់នៃការបន្តការអប់រំនយោបាយ ពាក់ព័ន្ធទៅនឹងមាគ៌ាបក្ស ដោយបានលើកឡើងសម្ដីដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "យើងត្រូវបន្តអប់រំលក្ខន្តិកៈ និងសេចក្ដីសម្រេចចិត្តរបស់សន្និបាតកងពលឲ្យបានជ្រួតជ្រាបតទៅទៀត ត្រូវមានផែនការរៀនសូត្រ១ខែម្ដងតាមឯកសារលក្ខន្តិកៈ។ សេចក្ដីសម្រេចចិត្តរបស់សន្និបាតកងពល មតិណែនាំផ្សេងៗរបស់សេនាធិការ ហើយត្រូវយកចិត្តទុកដាក់ ចាត់តាំងរៀនសូត្រទង់បដិវត្តយុវជន យុវនារីបដិវត្ត និងកាសែតបដិវត្ត ឲ្យកម្មាភិបាល និងយុទ្ធជន យុទ្ធនារីជាបន្តបន្ទាប់"។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដី។

ឯកសារមួយទៀត ដែលខ្ញុំសូមបង្ហាញ គឺឯកសារលេខ E3/798។ កំណត់ហេតុកិច្ចប្រជុំកងពលនិងកងវរសេនាធំ លេខាកងពល និងអនុលេខាកងពលនេះ និងកងវរសេនាធំ។ ប្រជុំនៅថ្ងៃទី៣០ខែ

សីហា ឆ្នាំ១៩៧៦។ នៅក្នុងកិច្ចប្រជុំនេះ ត្រង់ទំព័រទី១នៃកំណត់ហេតុ សុន សេន ឬក៏បង៨៩ រាយការណ៍ពីសភាពការណ៍ខ្មាំងតាមមូលដ្ឋាន និងតាមអង្គភាពទ័ព។ គាត់បានលើកឡើងអំពីការចាប់ខ្លួនបុគ្គល១០០នាក់ ដែលបានចូលរួមបះបោរនៅព្រំដែនកណ្ដាលស្ទឹងតំបន់៦៣។ ហើយនិងការចាប់ខ្លួននៅតំបន់២៥ ដែលគាត់បានរៀបរាប់នៅក្នុងនេះដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ពួកវាលើកទង់ស មានពាក្យស្លោក ជយោ! ពុទ្ធសាសនា! ជយោ! រណសិរ្សខ្មែររំដោះអង្គការទ័ព! វាបម្រុងបះបោរធំ ថ្ងៃ២០ សីហា"។ សូមបញ្ចប់ការដកស្រង់សម្ដី។

[០៩:២៣:១១]

សុន សេន បានលើកឡើងនៅក្នុងកិច្ចនោះទៀតថា និយាយអំពីទំនាក់ទំនងនៃសភាពការណ៍នេះជាមួយនឹងខ្មាំង ហើយគាត់បានបញ្ជាក់ថា បុគ្គលដែលត្រូវបានចាប់ខ្លួនមួយចំនួន នោះបាននិយាយនៅក្នុងហ្នឹងថា មេដឹកនាំនោះគឺមាន ចក្រី ដែលនេះសំដៅទៅលើលេខាកងពលតំបន់១៧០ ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំនោះ។ កិច្ចប្រជុំនោះបានលើកឡើងអំពីវិធានការ៥ ដែលបានលើកឡើងដោយ សុន សេន ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍នោះ។ ដែលយើងអាចមើលឃើញត្រង់ខ្មែរទំព័រ ERN លេខ 00052380 ទៅដល់ 52381, អង់គ្លេសមានលេខ 00183966, បារាំងមានលេខ 00386196 ទៅដល់ 97។

វិធានការទី១ ដែលស្នើឡើងដោយ សុន សេន មានដូចតទៅ៖ អប់រំបន្ថែម -- អប់រំស្មារតីប្រុងប្រយ័ត្នថែមទៀតកុំឲ្យសន្តិភាពនិយម។ វិធានការទី៣ បានសរសេរថា "កងពលពិនិត្យតាមដានសមាសភាពមិនល្អ ចាត់តាំងគ្រប់គ្រងឲ្យនៅដោយឡែក"។

[០៩:២៤:៥៣]

នៅក្នុងចំណុចក្រោយទៀតនៃឯកសារនេះត្រង់ទំព័រខ្មែរ 00052382, អង់គ្លេសមានលេខ 0018 3968, បារាំងមានលេខ 00386199។ សុន សេន បានលើកឡើងដូចតទៅ សូមដកស្រង់សម្ដី "ខ្មាំងវាចង់ឆ្លៀតប្រមូលពួកសមាសភាពមិនល្អ មុខមាត់ បុណ្យស័ក្តិ ត្រូវគ្រួសារយើងបោសសម្អាត។ ពួកត្រូវយើងដកពីតំណែង ពួកដែលមិនយល់ជ្រួតជ្រាបចលនាបដិវត្តន៍ដើរមិនទាន់គេ ហើយទន្ទឹមនេះពួកប្រជាជនថ្មីដែលពុំទាន់យល់ ត្រូវយើងកំពុងលំបាកខ្វះខាតស្បៀងបណ្ដោះអាសន្ន"។ បញ្ចប់ការដកស្រង់សម្ដី។ បន្តនៅក្នុងចំណុចកថាខណ្ឌមួយទៀត គឺថាវិធានការចំណុចខ បាននិយាយថា "ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អតទៅទៀត ត្រូវដាច់ខាត តែកុំឆ្វេង"។

[០៩:២៦:២៨]

ឯកសារមួយទៀតគឺ E3/1133 គឺជាឧទាហរណ៍នៃរបាយការណ៍លម្អិត ដែលផ្ដល់ជូនដោយទៀងទាត់ដោយកងពល ដែលក្នុងនោះនិយាយអំពីបញ្ហាចាប់ខ្លួន និងការសួរចម្លើយខ្មាំង។ គឺរបាយ-ការណ៍ចុះថ្ងៃទី០១ កញ្ញា ឆ្នាំ១៩៧៦ ពីកងពល៥០២ ដែល -- ពីកងពល ស៊ូ ម៉េត ៥០២ ដែលក្នុងនេះរៀបរាប់លម្អិតអំពីការចាប់ខ្លួនទាហានពីរនាក់ ដែលបានលួចមាន់ អង្ករ អាវុធកាំភ្លើង ហើយក៏បានរាយការណ៍អំពីចម្លើយសារភាព ដែលក្នុងចម្លើយសារភាពនោះបាននិយាយអំពីបណ្ដាញ និងខ្មាំងទាំងឡាយដែលក្រោយមកត្រូវបានចាប់ខ្លួនផងដែរ។

ឯកសារ E3/813 គឺកំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ និង សុន សេន ដែលប្រជុំនៅថ្ងៃ០៩ ខែកញ្ញា ឆ្នាំ១៩៧៦។ នៅក្នុងកិច្ចប្រជុំនេះ កងពល១៦៤ រាយការណ៍លម្អិតអំពីស្ថានភាពខ្មាំងនៅក្នុងតំបន់របស់ខ្លួន ដែលក្នុងនោះរួមទាំងការចាប់ទូកតូចមួយ ដែលក្នុងនោះមានជនជាតិថៃប្រាំនាក់ និងជនជាតិខ្មែរមួយរូប នៅកោះរ៉ុងសន្លឹម។ ការរាយការណ៍អំពីស្ថានភាពនេះ សុន សេន បានស្នើនូវវិធានការដូចតទៅ នៅក្នុងចំណុច៤.១ នៃរបាយការណ៍កំណត់ហេតុនេះ។ សូមដកស្រង់សម្ដី "ស្នើខាងសមុទ្រប្រុងប្រយ័ត្នថែមទៀត។ ពួកទូកចូលមកកោះរ៉ុងសន្លឹម បញ្ជូនមកឱ្យសួរចម្លើយ"។ បញ្ចប់ការដកស្រង់សម្ដី។

[០៩:២៨:៤៩]

របាយការណ៍មកពីកងពល១៦៤ នៅក្នុងកិច្ចប្រជុំដដែលនោះ ក៏បានបញ្ចូលនូវការថ្លែងនូវចំណុចបីនៃកំណត់ហេតុនេះផងដែរ។ "ក្នុងប្រជាជននេះភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ ថ្មីៗនេះរកឃើញទាហានស័ក្ដិ២ ពីរនាក់ដែលបានចាប់ហើយ" សូមបញ្ចប់ការដកស្រង់សម្ដី។ នៅក្នុងថ្ងៃដដែលនោះ ថ្ងៃ០៩ ខែកញ្ញា ឆ្នាំ១៩៧៦ សុន សេន បានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយនឹងកងពល ៧០៣ លេខា គឹម, ប្រធានស-២១ គឺ ឌុច និងប្រធានស-៧១ គឺ ប៉ង់ ដែលកំណត់ហេតុនេះចុះនៅក្នុងឯកសារលេខ E3/811។ កិច្ចប្រជុំនេះរួមមាន លិខិត ឬឱត្តប័ណ្ណមួយចំនួនដែលឃើញនៅជិតវត្តបទុម និងជិតទីក្រុងភ្នំពេញ ២ថ្ងៃមុន។

នៅក្នុងកិច្ចប្រជុំនេះ ប្រធានស-២១ គឺឌុច បានកត់សម្គាល់ថា កម្មាភិបាលមកពីកងពល១៧០ គឺកងពលរបស់ ចក្រី ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធទៅនឹងហេតុការណ៍មុនៗនៃការបាចខិតប័ណ្ណ។ សុន សេន ដែលក្នុងនោះបានលើកឡើងអំពីបណ្ដាញខ្មាំងពីរ ដែលត្រូវទទួលខុសត្រូវលើសភាពការណ៍នេះ។

ទី១ គឺជាប់ពាក់ព័ន្ធទៅនឹងកងពល១៧០ ឬក៏កងពល៧០៣ ចេញមកពីតំបន់២៥។ វិធានការដែលបាន ស្នើឡើងនៅពេលនោះ ហើយបានកត់ត្រានៅចំណុចចុងក្រោយនៃរបាយការណ៍នេះបង្ហាញឲ្យយើងឃើញ យ៉ាងច្បាស់។

[០៩:៣០:៥៦]

ខ្ញុំនឹងដកស្រង់សម្តី "ពាក់ព័ន្ធទៅនឹងការចាត់តាំងសមមិត្ត ប៉ង់ ត្រូវតែទទួលស្គាល់ភារកិច្ចធ្ងន់ធ្ងរ របស់ខ្លួន ហើយត្រូវធ្វើការ ធ្វើមនោគមន៍វិជ្ជា អប់រំមនោគមន៍វិជ្ជាឲ្យបានបន្ត និងរឹងមាំ ហើយធ្វើយ៉ាង ណាក្តោបប្រវត្តិរូបឲ្យបានជាក់លាក់។" បញ្ចប់ការដកស្រង់សម្តី។ ពាក់ព័ន្ធទៅនឹងកងពល៧០៣ ពីន គឺ និយាយអំពីការពិនិត្យនៅក្នុងអង្គភាពនេះ និងការតាមដានឲ្យបានជាក់លាក់។ វិធានការចុងក្រោយដែល បានលើកឡើងនៅក្នុងកិច្ចប្រជុំនេះមានដូចតទៅ។ សូមដកស្រង់សម្តី "ពាក់ទៅនឹងបញ្ហាសន្តិសុខខ្ញុំស្នើ ថា ត្រូវបង្កើនការតាមដានខ្លាំង។ ខ្ញុំស្នើថា ឲ្យ ប៉ង់ ធ្វើការទាក់ទងជាមួយនឹងក្រសួងផ្សេងៗ។ កងពល ១៧០ហ្នឹងត្រូវតែព័ទ្ធដើម្បីចាប់នៅនឹងមួយកន្លែង។

១អាទិត្យក្រោយមក នៅក្នុងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ កិច្ចប្រជុំមួយត្រូវបានប្រជុំរវាង សុន សេន, ឌុច, លេខាកងពល១៧០ សុត និង តាល់ កងពល២៩០" ដែលមានសរសេរនៅក្នុងឯកសារ E3/822។ កិច្ចប្រជុំនេះបានរៀបរាប់អំពីការចាប់ខ្លួនថ្មីៗ នៃចាប់ខ្លួនលេខា២៤ ឈ្មោក ដែលត្រូវបាន ចក្រី ឆ្លើយដាក់។ កិច្ចប្រជុំនោះបានយោងជាក់លាក់ទៅលើផែនការដែលអង្គការបានចែកចាយស្របទៅតាម ខ្សែបណ្តាញ ចក្រី ទាំងអស់ដែលត្រូវប្រមូល និងចាប់ខ្លួន។ កិច្ចប្រជុំនោះបានឯកភាពចាប់កម្មាភិបាល បួននាក់ មកពីកងពល៧៩០ និងចេញមកកងពល១៧០ ហើយត្រូវចាប់ខ្លួនប្រពន្ធ និងក្មួយរបស់ ចក្រី។ កិច្ចប្រជុំនោះក៏បានកត់សម្គាល់ផងដែរថា មានកិច្ចប្រជុំមួយ រៀបចំ១ថ្ងៃមុនដែលត្រូវចាប់ខ្លួនបុគ្គល បន្ថែមចេញមកពីកងពល១៧០ ដែលត្រូវបានសម្រេចរួចមកហើយ។

[០៩:៣៣:៣៧]

ឯកសារ E3/800 គឺឯកសារបន្ទាប់មួយទៀតដែលខ្ញុំនឹងបង្ហាញ ឯកសារ E3/800 គឺកំណត់ ហេតុកិច្ចប្រជុំកងពល និងកងវរសេនាធំឯករាជ្យ លេខា និងអនុលេខាកងវរសេនាធំឯករាជ្យ ដែលបាន ប្រជុំនៅថ្ងៃ១៦ ខែ៩ ១៩៧៦ ពេលល្ងាច។ នៅក្នុងចំណុចទី៣ នៃសេចក្តីបញ្ចប់របស់បង៨៩ ចំណាងជើង ថា "ពិនិត្យកងទ័ពរបស់យើង"។ សុន សេន បានឲ្យចាប់អារម្មណ៍ថា កងទ័ពមានសមាសភាពមិនល្អ និងពួក១៧ មេសា មកពីទីក្រុងភ្នំពេញ។ ហើយបង៨៩ ស្នើសុំនូវវិធានការដូចតទៅ សូមដកស្រង់សម្តី

"ត្រូវតាមដានប្រវត្តិរូបកងទ័ពឲ្យច្បាស់ ហ្មត់ចត់ ពិសេសពួកយើងបញ្ចូលថ្មី ដោយទូងស្គរប្រមូលក្រោយរំដោះទូទាំងប្រទេស" បញ្ចប់ការដកស្រង់សម្តី។

[០៩:៣៥:០៣]

ឧទាហរណ៍ល្អមួយទៀត គឺនិយាយអំពីរចនាសម្ព័ន្ធ និងកំណត់ហេតុលម្អិតរបស់លេខាកងពលនៅកិច្ចប្រជុំរួមជាមួយនឹង សុន សេន គឺឯកសារ E3/810 ជាកំណត់ហេតុនៃកិច្ចប្រជុំលេខា និងភស្តុភាររបស់កងពលនៅថ្ងៃទី១៩ ខែសីហា ៧៦។ កំណត់ហេតុនេះបង្ហាញថា តើកងពលនីមួយៗ ក៏ដូចជាកងវរសេនាធំឯករាជ្យរាយការណ៍អំពីស្ថានភាពនៅក្នុងអង្គភាពរបស់ខ្លួន ដោយគ្របដណ្តប់ទៅលើប្រធានបទដូចខាងក្រោម។

ទី១ និយាយអំពីស្ថានភាពខ្មាំង សភាពការណ៍ខ្មាំង

ទី២ និយាយអំពីស្ថានភាពបង្កបង្កើនផល ដោយមានរៀបរាប់អំពីបញ្ហាសុខភាព ការផ្គត់ផ្គង់ស្បៀងអាហារ និងបញ្ចប់ទៅដោយស្ថានភាពរបស់នៅក្នុងជួរបក្ស។

[០៩:៣៦:០៨]

កំណត់ហេតុនេះគេនិយាយអំពីការផ្តល់ស្បៀងដោយមានកម្រិត ហើយនិងបញ្ហាសុខភាពនៅក្នុងកងទ័ព។ កងពល -- លេខាកងពល១៧០ គឺសូមដកស្រង់ "បងប្អូនឈឺ៤០ភាគរយ។ ជំងឺមានហើមរាកមួល និងគ្រុនចាញ់។ ខែនេះពលីអស់១០នាក់ហើយ"។ លេខាកងពល៣១០ អឿន សូមដកស្រង់ "បងប្អូនប្រុសស្រីឈឺ២.៦០០នាក់ ធ្ងន់ធ្វើការមិនកើតសោះ៤០០នាក់" គាត់ក៏បានរាយការណ៍ សូមដកស្រង់ "ស្បៀងដែលបានផ្គត់ផ្គង់ទាំងអស់ គឺបានហូបចុកអស់ហើយនៅក្នុងខែកញ្ញានេះ"។ លេខាកងពល៤៥០ ឈ្មោះសឿង "នៅកងពលមានឈឺ៣០០នាក់ រួមទាំងអ្នកនៅកងវរសេនាតូចសរុបទាំងអស់គឺឈឺ១.០០០នាក់ វរសេនាធំគឺឈឺ១.០០០នាក់។ ស្បៀងដែលបានផ្តល់ពីភស្តុភារកងពលគឺថាអស់ហើយ យើងមិនអាចផ្គត់ផ្គង់ស្បៀងអាហារដោយខ្លួនឯងបានទេ"។ បញ្ចប់ការដកស្រង់។

ឯកសារ E3/1024 និង E3/1101 ខ្ញុំសូមបង្ហាញឡើងវិញម្តងទៀត E3/1024 និង E3/1101 គឺជាឧទាហរណ៍នៃសេចក្តីណែនាំសរសេរដោយដៃ ដែលផ្ញើដោយ សុន សេន តាមរយៈសារទូរលេខទៅដែលចេញពីបញ្ជាការដ្ឋានមជ្ឈិម។ ឯកសារទាំងពីរនេះ និយាយអំពីសារទូរលេខដូចគ្នាតែមួយ ដែល សុន សេន បានផ្ញើជូនទៅដោយក្រោមរហស្សនាមរបស់គាត់ហៅ ខៀវ នៅថ្ងៃទី២៣ ខែកញ្ញា ៧៦ ជម្រាបសមមិត្ត អឿន និងលេខាកងពល៩២០ ឈ្មោះ ឈិន។ សុន សេន បានផ្ញើជូនកងពលទាំងពីរនេះ

ទាក់ទងទៅនឹងពួកខ្មាំងសើរើ ជាពិសេសពួកយួន គឺពិសេសពួកប្រាំពីរ ដែលវាប្រព្រឹត្តសកម្មភាពទាក់ទងព្រមជាមួយនេះវាមានការទាក់ទងជនក្បត់ខ្លះ ដើម្បីបំផុសក្នុងជួរប្រជាជនប្រឆាំងសហករណ៍ ប្រឆាំងមាគ៌ាបដិវត្តន៍សង្គមនិយមរបស់យើង និយាយរួម ពិសេសបង្កប់ស៊ីរូងយូរអង្វែង។

[០៩:៣៩:៣៤]

នៅក្នុងសារទូរលេខនេះ សុន សេន បានណែនាំ សូមដកស្រង់ "ត្រូវតាមដានសមាសភាពណាដែលទាក់ទងនឹងពួកប្រាំពីរ ឬមាននិន្នាការនិយមពួកប្រាំពីរ ដើម្បីសម្រិតសម្រាំងកុំឲ្យមានតួនាទីដឹកនាំនៅក្នុងថ្នាក់ណានៅក្នុងកងទ័ពឲ្យសោះ"។ ចំពោះអ្នកទាំងអស់នេះ សុន សេន បានបញ្ជាឲ្យកងពល ៨១០(ស៊ីក) និង៩២០ មិនត្រូវអនុញ្ញាតឲ្យពួកវាស៊ីរូងផ្ទៃក្នុង ក្នុងជួរកងទ័ព ឬយុទ្ធជនរបស់យើង ជាពិសេស មិនត្រូវអនុញ្ញាតឲ្យពួកវាមានការទាក់ទងជាមួយនឹងកងពលទាំងអស់នៅតាមព្រំដែនជាដាច់ខាត។

ឯកសារ E3/801 ជាកំណត់ហេតុនៅថ្ងៃទី៣០ ខែកញ្ញា ៧៦ ជាកិច្ចប្រជុំរវាងសេនាធិការជាមួយខាងផ្នែកភស្តុភារ ជាមួយនិងមន្ទីរ៦២។ ខ្ញុំសូមស្នើសុំឲ្យធ្វើការចាប់ខ្លួន ដោយរួមទាំងស-២១ ដែលយើងអាចរកឃើញនៅក្នុងត្រង់ផ្នែកទី១ នៃកំណត់ហេតុនេះ និយាយរាយការណ៍អំពីសភាពការណ៍ខ្មាំងនៅក្នុងអង្គភាពរបស់ខ្លួន។ ឧទាហរណ៍ កងពល៣១០ និយាយពីពួកសមាសភាពមិនល្អ ដែលត្រូវយកមកធ្វើការអប់រំជាច្រើនលើកច្រើនសា ហើយ សុន សេន គឺបានណែនាំពាក់ព័ន្ធទៅនឹងបុគ្គលទាំងអស់នេះ។ កងពល១៧០ បាននិយាយអំពីការចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅថ្ងៃទី២៤ ខែកញ្ញា។

[០៩:៤១:៤០]

ឯកសារ E3/820 ៗ គឺជាសេចក្តីរាយការណ៍នៅថ្ងៃទី០១ តុលា ១៩៧៦ ដែលបានផ្តល់សក្ខីកម្មដោយសាក្សី អ៊ុង រ៉ែន គឺកងពល១៧០ គឺជាកងពលដែលបានបញ្ជាដោយចក្រីកាលពីពេលមុននោះ។ នៅក្នុងផ្នែកទី១ នៃរបាយការណ៍របស់ រ៉ែន គឺនិយាយអំពីការតាមដានទៅលើសកម្មភាពកងពលខែមុននេះ គឺកថាខណ្ឌ"ង" និយាយថា "ការអនុវិន័យរបស់បក្ស បានតាមសេចក្តីសម្រេចរបស់បក្ស ដូចជាដកហូតកម្មាភិបាលដែលមាននិន្នាការនយោបាយមិនល្អ" បញ្ចប់ការដកស្រង់។ ផ្នែកទី៣ នៃសេចក្តីរាយការណ៍នេះ រៀបរាប់អំពីកិច្ចប្រជុំទិតៀន និងស្វ័យទិតៀន ដែលលេខាកងពលឈ្មោះ សុខ រិះគន់ដោយសារការរៀបរាប់ប្រវត្តិរូបមិនបានល្អ។ សូមដកស្រង់ "គឺអាចក្រី ពួកអាទាក់ទងអាចក្រី ជាពិសេសដៃជើងអាចក្រី ហើយនៅចុងបញ្ចប់នៃរបាយការណ៍និយាយកម្មាភិបាលផ្សេងៗដែលមកពីកងពលនេះ

E1/162.1

ដែលត្រូវបានបញ្ជូនមកកន្លែងអប់រំរបស់កងពល"។ បញ្ចប់ការដកស្រង់។

[០៩:៤៣:២៥]

ឯកសារ E3/1225 គឺ E3/1225 ជាកិច្ចប្រជុំថ្ងៃទី០៦ ខែតុលា ៧៦ សារទូរលេខមកពីកងពល១៦៤ ដែលផ្ញើជូន ជូនបងមុត។ ចម្លងជូនបងនួន និងបងខៀវ។ កថាខណ្ឌ៣ នៃទូរលេខនេះនិយាយអំពីការប្រើប្រាស់ក្មេងៗដើម្បីឲ្យធ្វើជាចោរ គឺថាចោរព្រៃទាំងអស់នេះ គឺថាយើងបានជួបពួកអាពួកក្បត់ដែលស៊ីរូងផ្ទៃក្នុងភូមិស្រុក ដែលមកទាក់ទងជាមួយនឹងពួកអាក្នុងព្រៃទាំងនេះ។

ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារ E3/13 ជាឯកសារដែលខ្ញុំសូមរៀបរាប់លម្អិតបន្តិច។ ឯកសារនេះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំថ្ងៃទី០៩ តុលា ៧៦ កិច្ចប្រជុំរវាងលេខា និងអនុលេខា និងវរសេនាធំឯករាជ្យ។

[០៩:៤៥:០០]

យោងទៅតាមរបៀបវារៈនៃកិច្ចប្រជុំនេះ របៀបវារៈទី១ និយាយអំពីបុណ្យខួបបក្សដែលនឹងត្រូវធ្វើនៅថ្ងៃទី១១ ខែតុលា របាយការណ៍នេះនិយាយអំពីការរំឭកខួបបក្ស ដែលថ្ងៃពិតប្រាកដគឺថ្ងៃទី៣០ ខែកញ្ញា តែត្រូវបានពន្យារ ដោយសារតែអង្គការជាប់រវល់"។ បញ្ចប់ការដកស្រង់។ ដើម្បីឲ្យយល់អំពីការដែលពន្យារបុណ្យខួបបក្សនេះ ខ្ញុំសូមត្រឡប់ថយក្រោយបន្តិច និងបង្ហាញជូននូវឯកសារពីរផ្សេងទៀត ដែលនិយាយអំពីព្រឹត្តិការណ៍កើតឡើងនៅប៉ុន្មានសប្តាហ៍មុនពេលដែលត្រូវប្រារព្ធខួបបក្សនេះ។

ឯកសារទី១ នោះគឺ D288/6.5/2.22 បាទ ខ្ញុំសូមថាឡើងវិញ D288/6.5/2.22 ជាចម្លើយសារភាពមកពីស-២១ របស់លេខាតំបន់២៤ ឈ្មោះឈូក ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី៣១ សីហា ១៩៧៦ ដែលត្រូវបាន សួរចម្លើយនៅស-២១ នៅក្នុងរយៈពេលប៉ុន្មានខែ ក្រោយខែកញ្ញាឆ្នាំ១៩៧៦ នោះ។ ឯកសារនេះគឺមានលេខ ERN ជាខ្មែរ គឺ 00038515 វាមាន -- គឺមាននៅក្នុងឯកសារចុះថ្ងៃទី ១៩ សីហា ១៩៧៦ ដែលមានចំណងជើងថា "គឺសារភាពជំហានដំបូងអំពីខ្សែចង្វាក់ចាត់តាំងផែនការកម្ទេចបងលេខ១ និងបងលេខ២ ពេលធ្វើដំណើរ ពេលសន្និបាតបក្ស ពេលបុណ្យខួបបក្ស ឬបុណ្យផ្សេងៗក្នុងឆ្នាំ១៩៧៦នេះ"។

[០៩:៤៧:២៧]

ឯកសារ ដែលខ្ញុំចង់បង្ហាញលម្អិតនោះគឺចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ជារបាយការណ៍ដែលសរសេរឡើងដោយឌុច ដែលផ្ញើជូនទៅបងជាទីគោរព។ របាយការណ៍ដែល ឌុច វាយការណ៍នេះ

គឺយើងមាន នៅត្រង់ខ្មែរ 003660 បាទ សូមកែតម្រូវឡើងវិញ 00038660 ដល់ 38667 ខ្មែរ, អង់គ្លេស 00831531 ដល់ 38 ។ កថាខណ្ឌទី១ ឌុចសរសេរថា "បងប៉ង់ បងផន នេះហើយជាអ្នកផ្តើមគំនិត ជាអ្នកចាត់ចែងយ៉ាងសកម្មម្នាក់ក្នុងការរៀបចំផែនការកម្ចាត់បងទី១ បងទី២ រូបបងផ្ទាល់ និងបង១ដឹកនាំខ្លះទៀត ដែលមានវណ្ណភាពដើមជាបញ្ញាជន"។ នេះគឺជាឯកសារដែលនិយាយអំពីព្រឹត្តិការណ៍ដែលកើតឡើងខាងដើមគឺ E3/192 នៅថ្ងៃទី២៧ កញ្ញា ៧៦។

បន្ទាប់ពីកាលបរិច្ឆេទនៃឯកសារនេះ ខ្ញុំនិយាយអំពីការរាយការណ៍របស់ឌុចជូនថ្នាក់លើ និយាយអំពីផែនការធ្វើ -- ផែនការសម្លាប់ ជាពិសេស ខៀវ សំផន បានថា "ប៉ុល ពត បានឈប់សម្រាកបណ្តោះអាសន្នពីតួនាទីជានាយករដ្ឋមន្ត្រី ដើម្បីថែទាំសុខភាពរបស់គាត់ ហើយក៏មានការប្រកាសថា នួន ជា គឺថាត្រូវបានចាត់តាំងឲ្យជំនួស ប៉ុល ពត ជាបណ្តោះអាសន្ន ក្នុងឋានៈជានាយករដ្ឋមន្ត្រីស្តីទីគឺចាប់ពីថ្ងៃទី២២ កញ្ញា ១៩៧៦"។ ការបង្ហាញឯកសារទាំងពីរនេះគឺដើម្បី ឲ្យយល់ពីអំឡុងពេលដែលការរៀបចំបុណ្យខួបបក្សនេះត្រូវបានពន្យារពីថ្ងៃទី៣០ កញ្ញា ទៅធ្វើនៅថ្ងៃទី១១ ខែតុលា វិញ។

[០៩:៥០:០០]

ចូលទៅដល់ឯកសារ E3/13 គឺជាកំណត់ហេតុនៃកិច្ចប្រជុំខែតុលា ៧៦ រវាងលេខា និងអនុលេខាកងពលទាំងអស់ គឺនៅមានត្រង់ ERN ខ្មែរ 00052405, អង់គ្លេស 00183984 និងបារាំង 00334974។ សុន សេន បានរាយការណ៍លម្អិតជូនទៅកងពល សូមដកស្រង់ "មានពួកបង្កប់នៅក្នុងបក្សដែលយើងមិនទាន់បានចាប់ខ្លួននៅឡើយ ហើយយើងបានដឹងតាមការសួរចម្លើយពួកវាទាំងអស់នេះ"។ ខ្ញុំសូមអានសេចក្តីដកស្រង់ខ្លះ១ពីរបាយការណ៍របស់ សុន សេន នេះ សូមដកស្រង់ "ទី១ គឺថាយើងបានចាប់ពួកស៊ីរូងផ្ទៃក្នុងនៅក្នុងកងពល១៧០ យើងត្រូវតែយកចិត្តទុកដាក់ ហើយរក្សាការសម្ងាត់ ហើយមិនត្រូវឲ្យព័ត៌មាននេះលេចឮទៅដល់ថ្នាក់ក្រោមនោះទេ"។ ដកស្រង់កថាខណ្ឌខាងក្រោម "ពីមុនគឺមានព្រឹត្តិការណ៍ផ្ទុះអាវុធនៅជិតសាលាវិចិត្រសិល្បៈ ហើយមានការចែកខិតប័ណ្ណនៅដើមខែមេសា ៧៦ គឺគេមានការគប់គ្រាប់បែក និងការបោះខិតប័ណ្ណ។ នេះគឺជាសកម្មភាពរបស់ពួកខ្មាំង ដែលពាក់ព័ន្ធនៅក្នុងចម្លើយដែលត្រូវចាប់ខ្លួនចំពោះអ្នកដែលពាក់ព័ន្ធជាមួយនឹងចក្រី"។ បញ្ចប់ការដកស្រង់។

[០៩:៥២:០៣]

ហើយអ្នកដែលបានចាប់ខ្លួនជាដំបូងបន្ទាប់ពីមានការផ្ទុះគ្រាប់បែកនៅក្បែរព្រះបរមរាជវាំង គឺមានកម្មាភិបាលឈ្មោះ យឹម សម្បត្តិ ឯកសាររបស់គាត់នៅ ស-២១ គឺ D288/6.5/2.14 គឺជារបាយ-

ការណ៍របស់ឌុច ចុះថ្ងៃទី៦ សីហា ៧៦។ របាយការណ៍នេះអាចរកឃើញនៅត្រង់ ERN ខ្មែរ 00245206 ដល់ 245211, អង់គ្លេស 00284003 ដល់ 08, បារាំង 00800759 ដល់ 64។ នេះគឺរបាយការណ៍ដែលឌុច ជាអ្នកសរសេរនៅខែសីហា ឆ្នាំ៧៦ ដែលរៀបរាប់លម្អិតអំពីប្រវត្តិរឿងរ៉ាវនៃការចាប់ខ្លួន និងចម្លើយសារភាពរហូតទៅដល់ការចាប់លេខាកងពល១៧០ ចាន់ ចក្រី។ នៅក្នុងឯកសារនេះ ឌុច បានបញ្ជូនឯកសារនេះទៅឲ្យថ្នាក់ដឹកនាំរបស់ខ្លួនដែលថា នៅក្នុង -- ដោយបន្ទាប់ពីការចាប់ខ្លួន ចាន់ ចក្រី នៅថ្ងៃទី២០ ខែឧសភា ៧៦។ ព័ត៌មាននៅក្នុងរបាយការណ៍នេះគឺស៊ីសង្វាក់គ្នាទៅនឹងរបាយ-ការណ៍របស់ សុន សេន ដែលផ្ញើជូនទៅកងពលនៅថ្ងៃទី១៩ កញ្ញា ៧៦។

[០៩:៥៤:១៧]

ហើយចូលទៅឯកសារ E3/19 នេះឡើងវិញ សូមកែប្រែ E3/13 នេះគឺ សុន សេន រាយការណ៍អំពីការចាប់ខ្លួន ចាន់ ចក្រី ដែលត្រូវបន្តធ្វើដូចតទៅ ហើយមាននៅ ERN ខ្មែរ 005240 ដល់ 52406, អង់គ្លេស 00183985, បារាំង 00334975។ នៅត្រង់ផ្នែកនៃកំណត់ហេតុនេះគឺសុន សេន រាយការណ៍ដូចតទៅ សូមដកស្រង់ នេះគឺជាសម្ដីរបស់ សុន សេន បន្ទាប់ពីការចាប់ខ្លួន ចាន់ ចក្រី។ “ពេលចាប់វា ឆ្លើយច្បាស់ថា វាជាខ្សែ សេ.អ៊ី.អា មេវាគឺ ឈូក លេខាតំបន់២៤។ យើងចាប់ ឈូក, ឈូក ឆ្លើយថាវាទាក់ទងវៀតណាម រៀបចំវាយក្បាលម៉ាស៊ីនដឹកនាំបក្សយើង។ វាវាយពីក្នុងវៀតណាមវាយពីក្រៅ។ យួន ឈ្មោះ ប៉ៃ ម៉ាប់, ឈូក ឆ្លើយមកដាក់ឈ្មោះ យ៉ា។ យើងបានចាប់ខ្លួន យ៉ា ហើយ យ៉ា ឆ្លើយថា វាក្បត់តាំងពីឆ្នាំ១៩៦២ ដែលមានម្នាក់ទៀតឈ្មោះ កែវ មាស។ ខ្សែនេះបង្កើតបក្សថ្មីតាំងពីឆ្នាំ១៩៦២ មក។ ខ្សែជាប់នឹង អ៊ឹម ឌិរ៉ៃ - គីម សែត។ ដូច្នេះ បញ្ហាបះបោរនៅកោះកុង បញ្ហាតំបន់២៤ ទំនាស់នឹងតំបន់៣៣ យើងឃើញច្បាស់អស់ហើយ។ ខ្សែមេៗយើងវាយកម្ទេចជាមូលដ្ឋានហើយ តែដៃជើងវានៅមានបន្តទៀត”។ បញ្ចប់ការដកស្រង់។

[០៩:៥៦:៤៤]

នៅទំព័របន្ទាប់គឺ ERN ជាភាសាខ្មែរ 7407 សុន សេន បានរាយការណ៍និយាយអំពីការជម្លៀសប្រជាជនពីតំបន់ជនបទ។ ជម្លៀសការប្រជាជនចេញពីទីក្រុងទៅកាន់ជនបទ។ សូមដកស្រង់ “តើមកពីយើងធ្វើបដិវត្តន៍និយមឬអី? បើយើងទុកប្រជាជន មិនជម្លៀសចេញពីក្រុងច្បាស់ជាមិនបានសុខសាន្តដូចសព្វថ្ងៃទេ។ បើយើងមិនដាច់ខាតធ្វើសហករណ៍ មិនដាច់ខាតធ្វើសង្គមនិយមទេ យើងមិនឈ្នះទេ យើងមិនសុខទេ”។ បញ្ចប់ការដកស្រង់។

នៅក្នុងចំណុចនេះបញ្ជាក់អំពីការកត់សម្គាល់និយាយអំពីលេខាកងពល និងវរសេនាធំ ដែលអនុវត្តតាមសេចក្ដីប្រកាសរបស់ សុន សេន បន្ទាប់ពីការចាប់ខ្លួនឈ្មោះ ឈូក និងឈ្មោះ យ៉ា គឺមាននៅត្រង់ ERN ភាសាខ្មែរ 0052408 (ស៊ីក), អង់គ្លេស 00183987, បារាំង 00334978។ កំណត់ហេតុនេះ គឺ សុខ មេកងពល១៧០ គឺបានកត់សម្គាល់ថា "កងពល១៧០ បានសម្រិតសម្រាំងពួកមិនល្អទុកមួយកន្លែងចំនួន។ លេខាកងពល១៧០ កម្មាភិបាលដែលធ្វើសកម្មភាពប្រឆាំង គឺដែលបញ្ចេញសកម្មភាពប្រឆាំងរបៀបមិនផ្សាយមាគ៌ារបស់បក្ស" ហើយនៅត្រង់អាកថាខណ្ឌបន្ទាប់ ភាសាខ្មែរគឺ 5 --

[០៩:៥៨:៥៩]

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន លោកសហព្រះរាជអាជ្ញាញាប់ពេក តាមអត់ទាន់។

**លោក ឌេល លីសាក់៖**

ERN ជាភាសាខ្មែរ 00052409, កំណត់ហេតុនៅត្រង់ផ្នែកនេះគឺនិយាយពីលេខាកងពលឈ្មោះពិន ដែលរាយការណ៍ សូមដកស្រង់ "បញ្ហាពួកក្បត់ និងវិធានការរបស់បក្ស ខ្ញុំយល់ស្របទាំងស្រុង។ មូលហេតុចំពោះអំពើក្បត់មកពីពួកទំនាស់មុខមាត់ និងបុណ្យស័ក្តិ។ ទោះបីយើងចាប់ពួកមេៗរបស់វាក៏ដោយ ពួកវានៅតែបន្តសកម្មភាព។ ចំពោះការបញ្ហាក្តាប់អង្គភាពក្រោយរៀនសូត្រ និងសម្រិតសម្រាំងជាបន្តបន្ទាប់ អាចធានាការពារបក្សបាន"។ បញ្ចប់ការដកស្រង់។ "លេខាកងពល៤៥០ សឿងមានសមាសភាពមិនល្អបានចាប់ខ្លួនហើយ ប៉ុន្តែមិនទាន់បោសសម្អាតនៅឡើយទេ បានក្តាប់ពួក សេរីមួយកម្រិត"។

[១០:០០:៣២]

ហើយទំព័របន្ទាប់មកទៀត ខ្មែរ 0052410 លេខាកងពល៣១០ អឿន បានធ្វើសេចក្តីរាយការណ៍ដូចខាងក្រោម សូមដកស្រង់ "កាលពីមុនគឺបក្សបានផ្តល់ការអប់រំជាម្តងហើយម្តងទៀត អំពីពួកក្បត់ផ្ទៃក្នុង និងផ្ទៃក្នុងអង្គការដឹកនាំកន្លងមក ដែលអំពីខ្មាំងស៊ីរូងផ្ទៃក្នុង។ ប៉ុន្តែពីមុនខ្ញុំបានយល់ឃើញថា គឺថាមានពួកក្បត់នៅក្នុងកម្រិតមួយដែលគួរឲ្យចាប់អារម្មណ៍ ដែលថ្នាក់ពួកក្បត់សំខាន់ៗ ជូនអង្គការបានព័ត៌មានមកដល់ថ្ងៃនេះ។ ប្រវិត្តរូបរបស់កម្មាភិបាលមួយចំនួន មិនទាន់ក្តាប់បាននៅឡើយទេ ហើយក៏មិនទាន់ដឹងថា ពួកគេច្បាស់ និងស្អាតស្អំ ឬក៏យ៉ាងនោះទេ។ មានពួកមួយចំនួនគឺថានៅលាក់ប្រវត្តិរូបរបស់ខ្លួន រហូតទៅដល់ថ្នាក់អង្គភាពថ្នាក់ក្រោម ហើយជាពិសេសពួកដែលធ្លាប់ ខ្មែរ-ស ដែលធ្លាប់រស់

នៅជាមួយវៀតណាម។ សរុបពួកមិនល្អបាន៣៦នាក់”។ បញ្ចប់ការដកស្រង់។

នៅទំព័របន្ទាប់ERN ជាភាសាខ្មែរ 00052411 លេខាកងពល ៥០២ ស៊ូ ម៉េត បានរាយការណ៍ដូចខាងក្រោម “ក្រោយបក្សបានបង្ហាញខ្សែពួកក្បត់ ជារបស់ពួកចក្រពត្តិអាមេរិក និងពួកសេរីនិយមបាន គឺខ្ញុំមានការស្មោះត្រង់ ទុកចិត្តជាមួយនឹងបក្ស។ ទាក់ទងនឹងបញ្ហានេះ កំណត់ថាយើងកម្ចាត់ខ្មាំងបានជាមូលដ្ឋានហើយ តែត្រូវមានវិធានការបន្តទៀត កុំឲ្យមានទី២ ទី៣ ទី៤ អ្វីបន្តទៀត។ គឺថាយើងត្រូវតែធ្វើការបោសសម្អាតជាដាច់ខាត”។

[១០:០២:៥៧]

នៅទំព័រដដែលនេះ លេខាកងពល១៦៤ មាស មុត បានរាយការណ៍ថា “ខ្ញុំសូមចាប់អារម្មណ៍ពីសកម្មភាពពួកក្បត់ក្នុងបក្ស។ ជាជ័យជម្នះមួយរបស់បក្សយើង មេរៀននេះបានពង្រឹងគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍មួយកម្រិតថែមទៀត។ គោល -- ចំពោះបញ្ហាក្តាប់អង្គភាព កម្មាភិបាលយុទ្ធជននៅមិនរឹងទេ។ សមាសភាពមិនល្អ ឬខ្មាំងនៅតែពួនបន្តំ បង្កប់ក្នុងជួរបក្សទៀត”។ បញ្ចប់ការដកស្រង់។

នៅក្នុងសេចក្តីបញ្ចប់សុន្ទរកថារបស់ សុន សេន ប្រជុំនៅថ្ងៃ០៩ ខែតុលា ឆ្នាំ៧៦ គាត់បានលើកឡើងនៅក្នុងចំណុចមួយ ត្រង់ខ្មែរលេខ ERN លេខ 00052412 រហូតទៅដល់ 52413, អង់គ្លេសមានលេខ 00018931, បារាំងមានលេខ 00334981។ នៅក្នុងកិច្ចប្រជុំនេះ សុន សេន បានលើកឡើងថា ខ្ញុំសូមដកស្រង់សម្តី “អង្គប្រជុំបានឯកភាពជាមួយបក្ស ចាត់ទុកការចាប់ពួកក្បត់នេះជាមហាជ័យជម្នះលើពួកសេរី -- លើពួកសើរីនិយមតាមផ្លូវសម្ងាត់ ហើយដែលវាបង្កប់ជាង១០ឆ្នាំហើយ”។ បន្តនៅក្នុងកថាខណ្ឌក្រោមបន្តិចបានសរសេរថា ដកស្រង់សម្តី “មេរៀនមួយទៀតនាំឲ្យយើងយល់សកម្មភាពវាយបដិវត្តន៍កំប៉ិកកំប៉ុក ដូចជាលួចនិយាយបញ្ជិតបញ្ឆៀងវាយបដវិត្តន៍ សុទ្ធតែចេញពីខ្សែក្បត់នេះ” បញ្ចប់ការដកស្រង់សម្តី។

[១០:០៥:២៣]

វិធានការដែលបានកំណត់នៅក្នុងចំណុចទី៣នៃសេចក្តីថ្លែងបញ្ចប់របស់ សុន សេន រួមមានវិធានការប្រតិបត្តិការដូចតទៅ ដែលលោក លោកស្រីចៅក្រមអាចមើលត្រង់ទំព័រ 00052414 វិធានការដែលបានស្នើឡើងនោះមានដូចតទៅ ខ្ញុំសូមដកស្រង់សម្តី “ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អដាច់ខាត ក្នុងន័យតស៊ូវណ្ណៈដាច់ខាត។ សម្រិតសម្រាំងត្រូវឈរលោកគោលការណ៍បីយ៉ាង។ ប្រភេទទី១ ពួកប្រភេទអន្តរាយ ត្រូវសម្រិតសម្រាំងដាច់ខាត។ ប្រភេទ២ ប្រភេទសេរីធម្មតា ត្រូវអប់រំ

ជាបន្តបន្ទាប់ក្នុងការអប់រំរបស់យើង។ ប្រភេទទី៣ ប្រភេទពួកទើបខ្លាំងញុះញង់ ទើបតែឈរគេញុះញង់ជាជំហានដំបូង។ ជាជំហានដំបូងត្រូវអប់រំកសាងគេ កុំឲ្យជឿខ្លាំងទៀត”។បញ្ចប់ការដកស្រង់សម្ដី។

[១០:០៦:៤០]

ឯកសារមួយទៀត ដែលខ្ញុំសូមពិនិត្យលើកឡើងបង្ហាញនោះ គឺឯកសារ E3/815 គឺជាកំណត់ហេតុរបស់លេខា និងអនុលេខាដែលបានប្រជុំនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ៧៦។ នៅក្នុងកិច្ចប្រជុំនេះ សុន សេន បានធ្វើការបង្ហាញពាក់ព័ន្ធទៅនឹងហេតុការណ៍ជួរក្បត់នៅក្នុងឃោឃា និងនៅក្នុងមូលដ្ឋានដែលវាពាក់ព័ន្ធទៅនឹងក្រុមពីរ គឺក្រុម សេ.អ៊ី.អា និងទី២ គឺពួកសេរីនិយមដឹកនាំដោយខាងសហភាពសូវៀត និងវៀតណាម។ កិច្ចប្រជុំបានឯកភាពលើវិធានការដូចខាងក្រោម ដែលអាចមើលឃើញត្រង់ទំព័រខ្មែរលេខ 00095529 ដល់ 95530, អង់គ្លេសមានលេខ 00877017, បារាំងមានលេខ 00623945 ដល់ 46។ វិធានការដែលបានលើកឡើងនៅក្នុងនេះ នៅក្នុងកំណត់ហេតុនេះមានដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី “ជាមួយទូទាំងប្រទេស ចាំសេនាធិការពិភាក្សាជាមួយភូមិភាគ បើកន្លែងណាក្នុងកងទ័ពមជ្ឈិមយើងលើកតែវិធានការ។ ពិសេសខាងការពារភ្នំពេញ។ មួយកងពលត្រូវរៀបចំកម្លាំងមួយវរសេនាតូចឲ្យមានអាវុធ គ្រប់រំសេវ រថយន្តប្រចាំការជានិច្ច។ កម្លាំងមួយវរសេនាតូចនេះ ដាក់ស្ដែងដំបូងរៀបចំមួយអនុសេនាធំឲ្យបានក្នុងសំណួមពរការពារប៉ុស្តិ៍វិទ្យុ កន្លែងអង្គការ និងកន្លែងសេនាធិការ។

[១០:០៨:៥៩]

ជ្រើសរើសមនុស្សឲ្យស្អាតខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង បំពាក់អនុសេនាអាវុធធ្ងន់ស្រាល, អាកា, ត្រីយ៉ើ, អឹម៧៩, បេ៤០, បេ៤១។ កម្លាំងនេះឲ្យបោះតាមមុខសញ្ញា ច្រកសំខាន់ៗរបស់ទីក្រុង ហើយទាក់ទងវិទ្យុភ្ជាប់ជាមួយសេនាធិការ។” បញ្ចប់ការដកស្រង់សម្ដី។

ឯកសារមួយទៀតគឺ E3/1135 គឺជាឧទាហរណ៍មួយទៀតដែលកងពលបានរាយការណ៍ជូន សុន សេន ហើយបន្ទាប់មក សុន សេន បានបញ្ជូនបន្តទៅឲ្យមេដឹកនាំបក្ស។ នៅក្នុងករណីនេះ គឺបញ្ជូនទៅឲ្យ នួន ជា។ គឺរបាយការណ៍នេះចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ៧៦ គឺចេញមកពីលេខាមុត លេខាកងពលគឺមុត ពាក់ព័ន្ធទៅនឹងបុគ្គលមួយចំនួនដែលបានគេចពីមន្ទីរពេទ្យ។

ហើយឯកសារមួយទៀត ដែលយើង ឯកសារនេះយើងអាចមើលខាងឆ្វេងនេះបាន។ យើងឃើញមានចំណារលាយលក្ខណ៍អក្សរ ដែលបានបញ្ជូននៅក្នុងថ្ងៃក្រោយមក គឺដោយ ខៀវ ដែលក្នុងនេះសរសេរថា “ជូន បងនួន ស្នើសុំស្វែងរកបុគ្គលពីរនាក់ ដែលបានរៀបរាប់នៅក្នុងរបាយការណ៍របស់

មាស មុត”។

ឯកសារ E3/1151 ៗគឺជាឧទាហរណ៍សារទូរលេខដែលបញ្ជូនពី សុន សេន ទៅកាន់លេខាកងពល១៦៤ មុត ដើម្បីទាក់ទង និងផ្តល់ការឯកភាពពាក់ព័ន្ធទៅនឹងវិធានការចាប់ខ្លួនចាប់ខ្លួន។ សារទូរលេខនេះគឺមកពីមុត ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដែលបានសរសេរនៅខាងឆ្វេង ខាងលើថា “មតិណែនាំទៅ១៦៤។” នៅក្នុងប្រយោគទី១ នៃសារទូរលេខនេះបានបញ្ជាក់យ៉ាងច្បាស់ថា សារទូរលេខនេះចេញមកពីលេខាកងពល១៦៤ គឺមុត ដែលជាអ្នកទទួលខុសត្រូវ។

[១០:១១:៥៩]

នៅក្នុងចំណុចទី៣ -- កថាខណ្ឌទី៣ សុន សេន បានឯកភាពវិធានការទាំងឡាយដែលមុត ស្នើឡើង។ ហើយនៅក្នុងនេះបានរៀបរាប់អំពីវិធានការពាក់ព័ន្ធទៅនឹងទូកដែលបានចូលមកដែនសមុទ្រកម្ពុជា។

ឯកសារ E3/1585 គឺជាបញ្ជីអ្នកចូលរួមនៅក្នុងវគ្គអប់រំសេនាធិការ ដែលចាប់ផ្តើមនៅថ្ងៃទី២០ ខែតុលា ឆ្នាំ៧៦។ ឯកសារ E3/847 និងឯកសារ E3/1142 វាជាកំណត់ហេតុអ្នកចូលរួមនៅក្នុងវគ្គអប់រំសេនាធិការលើកទី២ ដែលបានរៀបចំឡើងនៅក្នុងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្ញុំមិនរៀបរាប់លម្អិតឯកសារទាំងពីរនោះទេ ក្រៅតែពីការបញ្ជាក់កាលបរិច្ឆេទ ដើម្បីជាប្រតិចារឹក សម្រាប់អង្គជំនុំជម្រះក្នុងការកំណត់អត្តសញ្ញាណកងពល និងកងវរសេនាធំឯករាជ្យមួយចំនួន។

បុគ្គលដែលពាក់ព័ន្ធនៅក្នុងកងពលតូច និងកងវរសេនាធំឯករាជ្យនោះគឺថា បង្កើតទៅជាកងទ័ពបដិវត្តន៍នៅក្នុងសម័យនោះ។ ឯកសារមួយទៀត ដែលខ្ញុំសូមលើកឡើងគឺឯកសារ E3/1164។ ឯកសារនេះគឺជារបាយការណ៍ចុះថ្ងៃទី២៥ ខែវិច្ឆិកា ៧៦ ពីលេខារឿន កងពល៨០១ ទៅបង៨៩ ត្រង់ខ្មែរ លេខ 0052327 (ស៊ីក) អង់គ្លេសមាន 00516711, បារាំងមានលេខ 00532754។ របាយ-ការណ៍នេះបានលើកឡើងវិធានការចាត់តាំងមួយចំនួនពាក់ព័ន្ធទៅនឹងខ្មាំងដែលបានស៊ីរូងនៅក្នុងកងពលដែលក្នុងនោះវិធានការរួមមាន “បុគ្គលទាំងឡាយដែលត្រូវបានសង្ស័យថាជាខ្មាំង ត្រូវចាប់ខ្លួនជាដាច់ខាត” បញ្ចប់ការដកស្រង់សម្តី។

[១០:១៤:៣៧]

ការចាប់ខ្លួននៅពេលនោះគឺថា វាពាក់ព័ន្ធទៅនឹងបុគ្គលទាំងឡាយណាដែលមានឈ្មោះនៅក្នុងឯកសារ។ នៅចុងបញ្ចប់នៃ នៅក្នុងឯកសារនេះ លេខាកងពល៨០១ លើកឡើងថា របាយការណ៍នេះជា

របាយការណ៍របស់គណៈកម្មាធិការ៨០១ ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់ខ្មាំងដូចដែលបានលើកឡើងខាងលើ “យើងខ្ញុំស្នើសុំឱ្យអ៊ំធ្វើជាយោបល់ យើងខ្ញុំរង់ចាំទទួលការណែនាំ និងអនុសាសន៍របស់បក្ស”។ បញ្ចប់ការដកស្រង់សម្តី។

ឯកសារ E3/804 គឺជាកំណត់ហេតុកិច្ចប្រជុំលេខា និងមន្ត្រីខាងលទ្ធកម្មនៅក្នុងកងវរសេនាធំដែលបានប្រជុំនៅក្នុងថ្ងៃ១៥ ខែធ្នូ ឆ្នាំ១៩៧៦។ នៅក្នុងកថាខណ្ឌ២(ក) នៃមតិយោបល់បញ្ចប់របស់បង៨៩ ពាក់ព័ន្ធទៅនឹងការងាររបស់បក្ស សុន សេន បានរៀបរាប់អំពីលទ្ធផល និងកិច្ចប្រឹងប្រែងក្នុងការសម្រិតសម្រាំងប្រវត្តិរូបរបស់កម្មាភិបាលយោធា ហើយកត់សម្គាល់ដូចតទៅ ដកស្រង់សម្តី “លទ្ធផលនៃការក្តោបប្រវត្តិរូបនៅពេលនេះ គឺល្អ ក៏ប៉ុន្តែនៅមានសមមិត្តមួយចំនួនដែលបានលាក់បាំងប្រវត្តិរូបរបស់ខ្លួន។ ជាពិសេសបុគ្គលទាំងឡាយដែលត្រូវឪពុកម្តាយរបស់ខ្លួន ឬបងប្អូនបង្កើតរបស់ខ្លួនត្រូវបានគេបោសសម្អាត។

[១០:១៦:២២]

នៅក្នុងកថាខណ្ឌទី៤ ពាក់ព័ន្ធទៅនឹងការបង្កើតយោធា សុន សេន បានណែនាំថា “ត្រូវរៀបចំអង្គភាពអន្តរាគមន៍ ត្រូវសម្រិតសម្រាំងឱ្យស្អាតស្អំ។ នៅពេលសេនាធិការបញ្ជូនបញ្ជាទៅកងពល ហើយកងពលបញ្ជូនបញ្ជានោះ គឺថាត្រូវតែចេញប្រតិបត្តិការ”។ បញ្ចប់ការដកស្រង់សម្តី។ សុន សេន ក៏បានរៀបរាប់នៅក្នុងចំណុច៣ នៃកំណត់ហេតុនេះ ពាក់ព័ន្ធស្តីអំពីការណែនាំរបស់បក្ស ដែលទទួលបាន ដែលក្នុងនោះអង្គការបានបញ្ជូនសេចក្តីសម្រេចមិនឱ្យធ្វើការកាន់អាវុធខ្លីទៅតាមខ្លួន ហើយការងារមួយចំនួនត្រូវរក្សាការសម្ងាត់។ ឧទាហរណ៍មួយចំនួននៃព័ត៌មានដែលបញ្ជូនតាមរបៀបណា? ទៅខាងលើនោះ គឺយើងឃើញមាននៅក្នុងឯកសារ E3/1079, E3/1132។ ឯកសារដំបូងគឺ E3/1079 គឺជារបាយការណ៍ដែលបញ្ជូនដោយលេខា៨ -- កងពល៨០១ គឺ រឿន បញ្ជូននៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ៧៦។ ឯកសារមួយទៀត ដូចគ្នា គឺឯកសារ E3/1132 ជារបាយការណ៍ដែលរៀបចំឡើងដោយសេនាធិការមានចំណងជើងថា “ស្ថានភាពរួមនៅក្នុងប្រទេស និងនៅតាមព្រំដែន” សារទូរលេខមក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦។

[១០:១៨:២៦]

នៅពេលដែលយើងប្រៀបធៀបឯកសារទាំងពីរនេះ យើងអាចមើលឃើញថា ព័ត៌មានទាំងឡាយដែលបានរាយការណ៍ដោយលេខាកងពល៨០១ នៅក្នុងឯកសារទី១ នោះ ជាពិសេសនៅក្នុង

កថាខណ្ឌ២, ៣, ៤ នៃរបាយការណ៍នេះ។ របាយការណ៍នេះ គឺបានទទួលយកដោយអគ្គសេនាធិការ ហើយក៏បានសរុបរួមទៅលើស្ថានភាពនៅក្នុងខែនោះ ដែលយើងអាចឃើញនៅក្នុងផ្នែកពាក់ព័ន្ធទៅនឹងកងពល៨០១ ត្រង់អគ្គសេនាធិការ -- មតិយោបល់របស់អគ្គសេនាធិការ។

នៅពេលនេះ ខ្ញុំសូមឱ្យពិនិត្យមើលឧទាហរណ៍មួយចំនួនទៀតពាក់ព័ន្ធទៅនឹងឯកសារយោធាមកពី ឆ្នាំ១៩៧៦។ ឯកសារ E3/107 គឺជាកំណត់ហេតុរបស់លេខាកងពល ដែលបានប្រជុំនៅថ្ងៃ១ ខែមីនា ឆ្នាំ៧៧ នៅក្នុងផ្នែកទីមួយនៃកំណត់ហេតុនេះ យើងឃើញមានការរាយការណ៍អំពីការបោសសម្អាតជាបន្តបន្ទាប់នៅក្នុងជួរយោធា។ ឧទាហរណ៍ កងពល៥០២ ម៉េត បានរាយការណ៍ថា "ជាក់ស្តែងធាតុ សមាសធាតុមួយចំនួនដែលយើងបានចាប់ខ្លួននោះ គឺជាសមាសភាពខ្មាំង ជាង៥០ គឺជាសមាសភាពមិនល្អ បានបញ្ជូនទៅ ស-២១ រួចហើយ។ យើងអាចទុកចិត្តបានប្រសិនបើកងអនុសេនាតូចប្រាំទៀតត្រូវបានដកខ្លួន។ លោក ឈឹម សមមិត្ត ឈឹម ដែលជាលេខាកងពលនោះត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅ ស-២១ ២អាទិត្យក្រោយមកផងដែរ"។ ដកស្រង់សម្តី "អ្នកដែលយើងចាប់បាន គឺមកពីជួរយួនអ្នកទាំងអស់នេះត្រូវ បានបោសសម្អាត និងសម្រិតសម្រាំងហើយឱ្យទៅធ្វើការងារកសិកម្មនៅទីកន្លែងមួយចំនួន។ សមមិត្ត យ៉ាន មកពីកងពល៤៥០ បានលើកឡើងថាប្រហែលជា ៦០០នាក់ គឺជាសមាសភាពមិនល្អដែលយើង ត្រូវដកចេញ"។

[១០:២០:៥១]

នៅក្នុងកិច្ចប្រជុំដដែលនេះគឺថា ខ្ញុំសូមឱ្យលោក លោកស្រីចៅក្រមមើលទំព័រ 00052306 និង 52308 ផងដែរ រហូតដល់ 09, អង់គ្លេសមានលេខ 00183951 រហូតទៅដល់53, បារាំងមានលេខ 00323925 រហូតទៅដល់27 បង៨៩ សុន សេន បានណែនាំកងពលដូចតទៅ សូមដកស្រង់សម្តី "ក្រោយពីយើងកម្ចាត់ពួកខ្សែក្បត់ឈូក និងអាយ៉ា មកយើងរកឃើញខ្សែក្បត់មួយទៀត យើង -- ត្រូវយើងកម្ទេចជាមូលដ្ឋាន"។ ក្រោយមកទៀត សុន សេន បានបន្តផ្តល់ប្រវត្តិលម្អិតអំពី ការបោសសម្អាតនៅក្នុងបក្សហើយគាត់បានស្នើសុំនូវវិធានការមួយចំនួន ខ្ញុំសូមដកស្រង់សម្តី "ត្រឹមតែ អប់រំនោះគឺមិនគ្រប់គ្រាន់នោះទេ វាចាំបាច់ត្រូវបន្តបោសសម្អាតបន្ថែមជាដាច់ខាត"។ សុន សេន ក៏បានណែនាំ នៅក្នុងកិច្ចប្រជុំនោះផងដែរថាភារកិច្ចនៅក្នុងការការពារប្រទេសនៅពេលនេះ គឺត្រូវមានអាទិភាព និងមានអាទិភាពខ្លាំងក្លាជាងការងារផ្សេងទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា។ នៅត្រង់ទំព័រ 00052310 សុន សេន បានកត់សម្គាល់ និងបែងចែករវាងទស្សនៈផ្ទុយគ្នា និងទស្សនៈនៅក្នុងបក្សដែលក្នុងនេះបានលើក

ឡើងថាត្រូវចាប់អារម្មណ៍លើទំនាស់បដិវត្តន៍ឲ្យដល់កម្រិត។ កន្លងមកយើងកម្ចាត់បានខ្សែក្បត់សំខាន់ៗច្រើន តែត្រូវប្រុងប្រយ័ត្នបដិវត្តន៍តទៅទៀត ពីព្រោះពួកសេសសល់នៅមាន ហើយពួកក្បត់ថ្មី នឹងកើតមានបន្តទៀត។ ទំនាស់ផ្ទៃក្នុងក៏នៅមានច្រើន ត្រូវការអប់រំតែទំនាស់ បដិបក្ខវាដើរតួខ្លាំងវាបំផ្លាញ យើងជាបាតុភាពច្រើនគ្រប់យ៉ាង" បញ្ចប់ការដកស្រង់សម្ដី។

[១០:២៣:៣៥]

ឯកសារ E3/1061 និងឯកសារ E3/1060 គឺជារបាយការណ៍មកពីកងពល ៨០១ បញ្ជូនទៅបង-៨៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ និងចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ ។ ឯកសារទាំងពីរនេះ គឺមានចំណារជាលាយលក្ខណ៍អក្សរដែលបានបញ្ជូនរបាយការណ៍ទាំងអស់នេះបញ្ជូនទៅអង្គការ។ នៅក្នុងចំណុចទី៣ នៃរបាយការណ៍ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ គឺឯកសារលេខ E3/1061 កងពល ៨០១ -- លេខាកងពល ៨០១ រឿន បានរាយការណ៍អំពីចាប់ខ្លួនអ្នកទោស ប្រាំពីរនាក់ អ្នកទោសយួន ប្រាំពីរនាក់ នៅតាមព្រំដែន ហើយបានបញ្ជូនទៅស្នួរចម្លើយ។

នៅក្នុងរបាយការណ៍ថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៧ គឺ ឯកសារ E3/1060 លេខា ៨០១ នេះ បាននិយាយអំពីសភាពការណ៍ខ្មែរនៅតាមភូមិភាគបូព៌ា រួមទាំងនៅតាមមូលដ្ឋានផងដែរ។ នៅភូមិភាគពីសាន។ ចំណារលាយលក្ខណ៍អក្សរនៅខាងឆ្វេង ខាងលើនៃទំព័រដំបូងនៃឯកសារ E3/1060 បានបញ្ជាក់អំពីស្ថានភាពនេះ។ ចំណារលាយលក្ខណ៍អក្សរនៅក្នុងទំព័រទី១ នៃរបាយការណ៍នោះគឺបានសរសេរថា "បញ្ជូនរបាយការណ៍ទៅអង្គការ"។ ហើយបានយោងចំណុចមួយសរសេរថា "ទួលស្លែង"។ នៅក្នុងកថាខណ្ឌនៃរបាយការណ៍នេះចុងក្រោយនេះ គឺនិយាយអំពីស្ថានភាពរបស់អង្គភាពនោះដូចតទៅខ្ញុំសូមដកស្រង់សម្ដី "យើងបានតាមដានទៅលើសមាសភាពទាំងថ្មីទាំងចាស់ ដែលបំផ្លាញបដិវត្តន៍របស់យើង គោលដៅសំខាន់នោះគឺអ្នកទាំងឡាយណាដែលប្រឆាំងនឹងមាគ៌ាបដិវត្តន៍ និងអ្នកទាំងឡាយណាដែលទើបតែ ឬក៏បានឆ្លើយដាក់ដោយខ្លាំងនាពេលថ្មីៗ និងនាពេលមុន"។ បញ្ចប់ការដកស្រង់សម្ដី។

[១០:២៥:៥៥]

ពាក់ព័ន្ធទៅនឹងរបៀបថា តើលេខាទទួលដំណឹងអំពីបុគ្គលទាំងឡាយដែលត្រូវបានឆ្លើយដាក់នៅក្នុងកងពលនោះ គឺថាខ្ញុំនឹងបង្ហាញឧទាហរណ៍មួយចំនួន ដែលក្នុងនោះនិយាយ និងសរសេរអំពីចំណារស-២១។ ចំណុចនេះគឺបានបង្ហាញថាតើលេខាកងពលនោះទទួលដំណឹងពីមន្ទីរដោយរបៀបណាចំពោះបុគ្គលដែលត្រូវបានគេឆ្លើយដាក់។ ចំណុចដំបូងគឺឯកសារ D43/IV ឧបសម្ព័ន្ធ២២។ នេះគឺជាចម្លើយ

សារភាព ស-២១ គឺចម្លើយសារភាពរបស់បុគ្គលមកពីកងពលមួយគឺឈ្មោះ គុណ ឌីម។ ឯកសារនេះមានលេខ 00175299, អង់គ្លេសមានលេខ 00224628, បារាំងមានលេខ 00271447។ យើងឃើញនៅក្នុងឯកសារនេះមានចំណារជាលាយលក្ខណ៍អក្សរនៅលើក្របដែលចារដោយ សុន សេន ទៅលេខាកងពល៨០១ រឿន "ជូនសមមិត្ត រឿន សូមសមមិត្តអានឯកសារ អាម៉ៅ ហើយស្រង់ឈ្មោះដែលទាក់ទងនឹងកងពល៨០១។ ស្អែកខ្ញុំជួបធ្វើការ ល្ងាចនេះខ្ញុំជាប់រវល់នៅឡើយ សូមរក្សាសម្ងាត់សិន"។ យើងឃើញថាឯកសារនេះចុះហត្ថលេខាដោយ ខៀវ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ៧៧។

ឧទាហរណ៍មួយទៀត គឺឯកសារ E3/150 គឺជាចម្លើយសារភាពស-២១ កងពល១៦៤ អនុលេខា ហង់ ឌឿន ហៅ ឌីម។ ចំណារដែលខ្ញុំសូមបង្ហាញនៅក្នុងឯកសារនេះត្រង់ទំព័រខ្មែរមានលេខ 00174375 គឺ 00174375, អង់គ្លេសមានលេខ 00224085, បារាំងមានលេខ 00235668។ ប្រសិនបើយើងមើលទៅលើចំណារនេះ មានសរសេរដូចតទៅ សូមដកស្រង់សម្ដី "ជូនបងជាព័ត៌មានអំពីផែនការគឺត្រូវហើយ ឬក៏ជាមនុស្ស ខ្ញុំសូមណែនាំ មុត ឲ្យធ្វើការពិនិត្យទៅលើបញ្ហានេះ"។ សូមបញ្ចប់ការដកស្រង់សម្ដី។

ឧទាហរណ៍មួយទៀត ពាក់ព័ន្ធទៅនឹងការសម្របសម្រួលរវាងមជ្ឈិម និងកងពល គឺពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពស-២១ ឯកសារ D43/IV ឧបសម្ព័ន្ធ ៩៩។ គឺឯកសារ D43/ -- បាទ សូមអធ្យាស្រ័យ គឺសហព្រះរាជអាជ្ញានិយាយដូច្នេះ។ គឺឯកសារ D43/IV ឧសម្ព័ន្ធ៩៩។ នេះជាចម្លើយសារភាពមួយរបស់លេខកងពល១៦៤ ឈ្មោះ គុណ ឌីម ត្រង់ក្របទំព័រនេះគឺមានលេខខ្មែរ ERN 00175293, អង់គ្លេសមានលេខ 00822359, បារាំងមានលេខ 00289872។ ទំព័រនេះយើងឃើញមានចំណារសរសេរដោយដៃ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ៧៧ ចុះហត្ថលេខាដោយ សុន សេន ដោយប្រើឈ្មោះរហស្សនាមថា ខៀវ។

[១០:៣១:០៤]

ចំណុចទី២ នៃចំណាររបស់ សុន សេន មានសរសេរដូចតទៅ "ក្រៅពីនេះជាប់ជាង២២ ប្លុកនិងកងពល១៦៤ របស់សមមិត្ត មុត"។ នៅក្នុងចំណុច៣ បានសរសេរថា "ទាក់ទងសមមិត្ត មុត ដើម្បីឲ្យចាត់វិធានការ។ យើងបានដកអស់ហើយអ្នកដែលនៅជាមួយនឹង មុត"។

ខ្ញុំសូមបញ្ជាក់ផងដែរថា នៅខាងលើទំព័រដដែលនេះ យើងឃើញមានចំណារមួយទៀត ដែលក្នុងនេះសរសេរអំពីការចម្លងជូន នួន -- ជូនបងនួន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ៧៧ ផងដែរ។ បន្ថែមទៅលើ

ចំណារដែលខ្ញុំទើបតែបានបង្ហាញនេះ យើងឃើញមានចម្លើយសារភាពរបស់ស-២១ ផ្សេងទៀត ដែលក្នុងនោះក៏បានមានចំណារដោយដៃផងដែរ ដែលចំណារទាំងអស់នោះបានសរសេរចម្លងជូនទៅកាន់លេខាកងពលពាក់ព័ន្ធ។ ឧទាហរណ៍ជាក់ស្តែងឯកសារលេខ D43/IV ឧសម្ព័ន្ធ៩១ គឺជាចម្លើយសារភាពរបស់ ជា សឿន លេខាកងវរសេនាធំ នៅក្នុងកងពល៧០៣។ ហើយនៅក្នុងនេះគឺខ្ញុំយោងទៅលើឯកសារត្រង់លេខខ្មែរ 00174986 ចំណារនៅក្នុងឯកសារនេះមានសរសេរថា "ជូន បងពីន មួយច្បាប់"។ ដូចគ្នានេះដែរ ឯកសារលេខ D302.5 គឺជាចម្លើយសារភាពរបស់កងពល៥០២ គឺចម្លើយសារភាពសមមិត្ត ស្រី សារឿន។

[១០:៣៣:១១]

នៅក្រោមចម្លើយសារភាពត្រង់ទំព័រ 00235162 យើងនឹងឃើញមានចំណារមួយសរសេរថា សូមដកស្រង់សម្តី "ជូនសមមិត្ត ម៉េត មួយច្បាប់"។ បញ្ចប់ការដកស្រង់សម្តី។

មុននឹងខ្ញុំបន្តទៅទៀត លោកប្រធាន ខ្ញុំមានឯកសារមួយចំនួនដែលត្រូវបង្ហាញទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធាពីឆ្នាំ១៩៧៧។ ខ្ញុំត្រូវបង្ហាញយ៉ាងតិចក៏៥ទៅ១០នាទីទៀត ថាតើលោកប្រធានអនុញ្ញាត ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានឯកសារមួយចំនួនទៀតដែលនៅសល់ពាក់ព័ន្ធទៅនឹងរយៈកាលឆ្នាំ១៩៧៧ ស្តីអំពីឯកសារយោធា។ ឯកសារទី១ គឺ E3/1168 របាយការណ៍ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៩ បញ្ជូនមកពីលេខាកងពល៨០១ រឿន ទៅបង៨៩។ នៅក្នុងឯកសារនេះ លេខាងកងពលបានស្នើសុំការឯកភាព សូមដកស្រង់សម្តី "សូមដកកងសមមិត្តកងពលតូច និងសមមិត្តមួយចំនួន ដោយសារតែការអនុវត្តមាគ៌ានោះគឺវាផ្ទុយ។ មហាជនគេមិនជឿ អប់រំកសាងមិនព្រមកែប្រែ ទិសវិវត្តន៍ថយក្រោយ"។ បញ្ចប់ការដកស្រង់សម្តី។

ឯកសារមួយទៀតគឺ E3/849 ឯកសារនេះគឺជារបាយការណ៍រៀបចំឡើងដោយអគ្គសេនាធិការខែមីនា ឆ្នាំ៧៧ ចំណងជើងថា "ស្ថិតិកម្លាំងរួម"។ ឯកសារនេះបង្ហាញអំពីចំនួនកម្លាំងនៅក្នុងកងពលកងវរសេនាធំឯករាជ្យ និងកងអនុសេនាធំរួម។ គឺមានកងទ័ព ៦១.១៨៩នាក់ នៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា។

[១១:០៣:៥៣]

ឯកសារ E3/1199 គឺជាសារទូរលេខបញ្ជូនមកលេខា សន កងពល៩២០ បញ្ជូនទៅបង៨៩ ចុះថ្ងៃ០៦ ខែមេសា ឆ្នាំ៧៧។ សារទូរលេខនេះបានរាយការណ៍ថា ក្រោយការអប់រំសមមិត្តកម្មាភិបាលកងពលរួចហើយ។ សូមដកស្រង់សម្តី "យើងឃើញមានការយល់ដឹងកាន់តែច្រើនក្នុងការទប់ទល់ជាមួយនឹងពួកក្បត់"។ សារទូរលេខនេះរួមមានចំណារដោយដៃ សរសេរដោយ សុន សេន ហៅ ខៀវ ដែលគាត់បានបញ្ជូនរបាយការណ៍នេះបន្តទៅឲ្យអង្គការនៅថ្ងៃបន្ទាប់។ បន្ថែមពីលើនេះ គឺមានចំណារមួយទៀត ដែលសរសេរថា សូមដកស្រង់សម្តី "ចាប់ខ្លួនពួកវាទៅ"។

ឯកសារមួយទៀតគឺ E3/1202 គឺជារបាយការណ៍ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ៧៧ បញ្ជូនទៅបង៨៩។ របាយការណ៍នេះបញ្ជូនមកពីលេខាកងពល១៧០ គឺសុក។ នៅក្នុងផ្នែកដំបូងនៃរបាយការណ៍នេះវាពាក់ព័ន្ធនឹងសភាពការណ៍ខ្មាំង។ របាយការណ៍នេះលើកឡើងអំពីខ្មាំង១១នាក់ ដែលមានគួរឲ្យព្រួយបារម្ភ ដែលសកម្មភាពរបស់អ្នកទាំងអស់នេះ គឺការនិយាយស្តី ការធ្វើដំណើរ និងការទាក់ទងដោយសេរី។ បញ្ចប់ការដកស្រង់សម្តី។

របាយការណ៍នេះក៏បានវាយការណ៍ត្រង់លេខ 00033309, អង់គ្លេសគឺមានលេខ 00828147, បារាំងមានលេខ 00623394។ យើងឃើញថានៅក្នុងទំព័រនេះគឺវាត្រឡប់ត្រឡិន អត់តាមលំដាប់លំដោយនោះទេ នៅពេលដែលយើងដាក់បញ្ចូលទៅក្នុងសំណុំរឿង។ របាយការណ៍នេះគឺបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ក្នុងគណៈកម្មាធិការបានឯកភាពគ្នាស្នើបញ្ជូនទៅស-២១។ ចំពោះឈ្មោះទាំងអស់នេះ ខ្លះនៅកំពង់ឆ្នាំងទើបតែឲ្យទៅយក។ បញ្ជាលម្អិតអំពីប្រវត្តិរូបសកម្មភាពម្នាក់ៗចាំធ្វើនៅក្រោយភ្ជាប់នឹងសាមីខ្លួន"។ សូមដកស្រង់សម្ដី នៅផ្នែកខាងក្រោយសរសេរថា សូមដកស្រង់សម្ដី "សូមស្នើមតិពីបង" បញ្ចប់ការដកស្រង់សម្ដី។

[១១:០៧:១៤]

ឯកសារមួយទៀតគឺ E3/1082 គឺជាកំណត់ហេតុថ្ងៃទី១២ ខែសីហា ឆ្នាំ៧៧ ដែលផ្ញើមកពីកងពល១៦៤ មុត ពាក់ព័ន្ធទៅនឹងស្ថានភាពការចាប់កប៉ាល់ថៃនៅព្រំដែនទឹកកោះកុង។ របាយការណ៍នោះបានរៀបរាប់ថា ជនជាតិថៃបួននាក់ និងខ្មែរម្នាក់ត្រូវបានចាប់ខ្លួនយកមកសួរចម្លើយ។ នៅខាងឆ្វេងរឹមទំព័រខាងឆ្វេងនៃឯកសារនេះ យើងឃើញមានចំណារសរសេរដោយដៃបញ្ជូនមកពី សុន សេន ហៅខៀវ បញ្ជូនទៅឲ្យអង្គការ ដោយក្នុងនោះស្នើសុំឲ្យស្វែងរកខ្សាំងផ្ទៃក្នុង ខ្សែខាងក្នុង"។ បញ្ចប់ការដកស្រង់សម្ដី។

លោកប្រធានជាទីគោរព! ឯកសារចុងក្រោយដែលខ្ញុំសូមបង្ហាញនៅក្នុងថ្ងៃនេះ គឺពាក់ព័ន្ធទៅនឹងឯកសារឆ្នាំ៧៧ គឺអំឡុងពេលដែលនៅក្នុងដីកាដំណោះស្រាយ ដែលថានៅពេលនោះ សុន សេន ត្រូវបានផ្លាស់ទីទៅភូមិភាគបូព៌ា ដើម្បីធ្វើការមើលស្ថានភាពជម្លោះជាមួយនឹងវៀតណាម ឯកសារនេះគឺ E3/195។

[១១:០៨:៥១]

ឯកសារនេះជាសារទូរលេខមកពីលេខាកងពល១៦៤ មុត ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ៧៧។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា សារទូរលេខនេះចេញមកពីលេខាកងពល ហើយមិនបានបញ្ជូនទៅបង៨៩ នោះទេ ប៉ែរជាសរសេរគោរពជូនគណៈ ម៨៧០។ ក្នុងនោះក៏មានការថតចម្លងជូនបងវ៉ាន់ បងនួន -- អ៊ំវ៉ាន់ អ៊ំនួន -- គឺមានចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ មន្ទីរ និងឯកសារ។ សារទូរលេខនេះបញ្ជូនទៅគណៈ ម៨៧០ លេខាមុត បានលើកឡើងដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី៖ "យើងខ្ញុំបានទទួលមតិណែនាំ និងសេចក្ដីថ្លែងការណ៍របស់បក្សស្ដីពីការឈ្លានពានរបស់យួន មកលេបទឹកដីមាតុភូមិ

កម្ពុជារបស់យើង។ យើងខ្ញុំដែលមានភារកិច្ចការពារមុខសញ្ញាសមុទ្រសូម៖ ១) ឯកភាពទាំងស្រុងជាមួយបក្ស។ ២) ប្តេជ្ញាកសាងកម្លាំងជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សមូហភាព និងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត។ ដោយបោសសម្អាតគ្មានស្ទាក់ស្ទើរសមាសភាពបង្កប់របស់ខ្មាំងជាយួន និងខ្មាំងដទៃទៀត”។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្តី។

[១១:១០:៣០]

លោកប្រធានជាទីគោរព ទាំងអស់នេះហើយ គឺជាឯកសារដែលយើងខ្ញុំសូមបង្ហាញ ហើយយើងខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារ។ យើងខ្ញុំសូមថ្លែងអំណរគុណនូវការផ្តល់ពេលវេលារបស់អង្គជំនុំជម្រះដើម្បីឲ្យយើងបង្ហាញអំពីឯកសារពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ ហើយយើងខ្ញុំដឹងថា យើងខ្ញុំត្រូវបង្ហាញអំពីឯកសារពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅដោយបង្ខំនោះទៀត ក៏ប៉ុន្តែខ្ញុំមិនដឹងថាតើពេលនេះគឺជាពេលសមស្របឲ្យខ្ញុំបង្ហាញតែម្តង ឬទុកពេលវេលាឲ្យខាងមេធាវីការពារក្តីជាអ្នកលើកយោបល់ ឬជំទាស់ជាមុនសិន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះយើងធ្វើមួយប្រធានបទម្តង ដើម្បីសម្រួលដល់ភាគីដែលពាក់ព័ន្ធផង ហើយក៏សម្រួលដល់កិច្ចដំណើរការនៃការពិភាក្សារបស់យើងផង។ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើមានបំណងចង់ធ្វើអត្ថាធិប្បាយ ឬក៏បន្ថែមអ្វីទៅលើបណ្តាឯកសារទាំងឡាយដែលដាក់បង្ហាញដោយតំណាងសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងអង្គហេតុ រចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យអម្បាញ់មិញនេះ។

[១១:១១:៥៧]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ យើងមិនទាន់ត្រៀមលក្ខណៈរួចរាល់ក្នុងការនិយាយស្តីអ្វីទៀតទេ ព្រោះថាខាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារអស់ហើយទាក់ទងទៅនឹងការជម្លៀស ហើយនិងរចនាសម្ព័ន្ធយោធានៅថ្ងៃនេះ។ ហើយយើងអាចធ្វើបាននៅរសៀលនេះ ព្រោះថាយើងស្មានតែខាងព្រះរាជអាជ្ញាហ្នឹងគាត់បង្ហាញឯកសារទាំងអស់តែម្តង។ អ៊ីចឹងខ្ញុំសូមសួរទៅអង្គជំនុំជម្រះថា តើឲ្យសហព្រះរាជអាជ្ញាបង្ហាញឯកសារគាត់ទាំងអស់ ហើយបន្ទាប់មក

យើងធ្វើបន្ត ឬក៏យ៉ាងម៉េច? ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

យើងបានឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញា សួរអម្បាញ់មិញហើយថា យើងធ្វើមួយប្រធានបទម្តង ដើម្បីសម្រួលនៅក្នុងការគ្រប់គ្រងដឹកនាំកិច្ចពិភាក្សានេះ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំ -- ក្រុមមេធាវីការពារក្តី ដោយចាប់ផ្តើមពីមេធាវីការពារក្តី នួន ជា មុនមេធាវីពីរក្រុមទៀតក្នុងការធ្វើអត្ថាធិប្បាយ ឬក៏ជំទាស់ចំពោះបណ្តាឯកសារភស្តុតាង ដែលតំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញពាក់ព័ន្ធទៅនឹងអង្គហេតុដែលរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ។

[១១:១៣:៤៧]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

នៅក្នុងការថ្លែងការណ៍របស់សហព្រះរាជអាជ្ញាដែលស្តីអំពីអត្ថបទ និងឯកសារដែលត្រូវដាក់យកមកជជែកគ្នានៅពេលនេះ ខ្ញុំជាមេធាវីការពារលោក នួន ជា សូមធ្វើការជំទាស់ទៅលើឯកសារមួយហើយនិងឯកសារមួយនេះ ជាដើមហេតុសម្រាប់ឯកសារតទៅទៀតរហូតដល់ទៅឯកសារលេខ៦៧ ប៉ុន្តែឯកសារនេះជាឯកសារដើមមួយដែលបានជជែកគ្នាពីមុនមករួចម្តងរួចទៅហើយ។ គឺតាំងពីឆ្នាំ -- ខែធ្នូ ថ្ងៃ១៥ ខែធ្នូ ឆ្នាំ១៩ -- ឆ្នាំ២០១១ គឺឯកសារ E3/5 ចុះថ្ងៃទី -- ខែសីហា ឆ្នាំ១៩៧០ -- សូមទោសអ៊ីចឹងហើយ ១៥ ខែធ្នូ ២០១១ នៅក្នុងប្រតិចារឹកដែលបានជជែកគ្នានៅវេលាម៉ោង ១២:២៤:០៦វិនាទី។ ឯកសារនេះ មានលេខ E3/5 និយាយអំពី “ទង់បដិវត្ត” ដែលមាន ERN 00063324 ដល់44 ហ្នឹងជាខ្មែរ និងជាអង់គ្លេស 00401489 និងបារាំង 00538963។ កាលពីឆ្នាំ២០១១ លោក នួន ជា ផ្ទាល់បានឡើងថ្លែងហើយធ្វើការជំទាស់យ៉ាងដាក់លាស់ ហើយនិងម៉ឺងម៉ាត់ បដិសេធឯកសារដែលយកមកដាក់មិនមែនជាឯកសារដើម គឺនិយាយអំពី “ទង់បដិវត្ត” ហ្នឹង។ លោក នួន ជា បាននិយាយថា “នៅក្នុងកថាខណ្ឌ២២ថា “សូមគោរពលោកប្រធាន ឯកសារទង់បដិវត្តនេះ មិនមែនធ្វើបែបនេះទេ ធ្វើជាឯកសារតែម្តង ធ្វើជាសៀវភៅ ហើយដូច្នេះ អានេះ មិនដឹងយកមកពីណា ខ្ញុំមិនដឹងដែរ។ អានេះមិនស្រប ជាសៀវភៅដែលធ្វើទង់បដិវត្ត ជាសៀវភៅ។ តើលោកមានទេ? ព្រោះអានេះអ្នកណាក៏ធ្វើបានដែរបោះពុម្ពនេះ”។

[១១:១៧:៣៧]

បន្ទាប់មកទៀត នៅថ្ងៃ១៥ ខែធ្នូ ២០១១ នៅពេលដដែលនោះ លោក នួន ជា បានបញ្ជាក់បន្ថែមថា នៅវាក្យខណ្ឌ២ នៅទំព័រលេខ៦៦ “ហ្នឹង ឲ្យជ្រះស្រឡះទាំងអស់គ្នា ព្រោះគោលការណ៍របស់តុលាការនេះចែងថា ស្វែងរកការពិត យុត្តិធម៌ ហើយខ្ញុំថែមទៀតថា មានប្រយោជន៍។ ដូច្នេះ ឯកសារអ្នកណាក៏ធ្វើបានដែរ បើតាមខ្ញុំមើល។ ដូច្នោះ បានជាខ្ញុំទទូចហើយទទូចទៀត សូមឯកសារដើមដែលបោះពុម្ពនោះ យកមកខ្ញុំមើល តើអ្នកណាសរសេរ? ហើយសរសេរយ៉ាងម៉េច? អានេះ បានជា -- បានវាជាក់ច្បាស់។ បញ្ជាក់ថាតុលាការនេះជាតុលាការស្វែងរកការពិតមែន ស្វែងរកយុត្តិធម៌មែន មិនមែនតុលាការក្លែងក្លាយទេ។ បើលោករកឯកសារការពិតមិនឲ្យខ្ញុំ ឯកសារដើមឲ្យខ្ញុំមិនបាន ខ្ញុំមិនទទួលទេឯកសារនេះ សូមបដិសេធ”។

ហើយនៅថ្ងៃដដែលទៀត នៅវេលាម៉ោង ១២:៣៦:០៣វិនាទី “នៅវាក្យខណ្ឌ២២ លោក នួន ជា បានមានប្រសាសន៍បន្ថែមកន្លះឃ្លាបន្តិច ប៉ុន្តែអ្នកៗកត់ត្រានេះ ចោលពាក្យបន្តិចមិនដឹងជាចោលដោយសារសម្តីលោក នួន ជា ហ្នឹង មិនច្បាស់ ឬយ៉ាងម៉េចមិនដឹង គ្រាន់ថា “មិន-- របស់ឯកសារទង់ក្រហមទេ”។ ខ្ញុំក៏ស្តាប់មិនបានដែរ មិនដឹងតុលាការវិនិច្ឆ័យថាយ៉ាងម៉េច ខ្ញុំមិនដឹងសន្និដ្ឋានថាម៉េច ខ្ញុំមិនបានខ្ញុំមិនយល់ដែរ។

[១១:១៩:៥៣]

ការបញ្ជាក់លោក នួន ជា ទាំងអស់នេះ សឲ្យឃើញថា ការជំទាស់របស់លោក នួន ជា លោក នួន ជា លោកមិនទទួលស្គាល់ឯកសារទង់បដិវត្តដែលសរសេរដោយលោកផ្ទាល់ជាមួយនឹងលោក ប៉ុល ពត នោះទេ។ ហើយតុលាការនៅតែទទូចយកមកដាក់ ហើយព្រះរាជអាជ្ញានៅតែយកសៀវភៅហ្នឹងមកចោទប្រកាន់ដើម្បីដាក់បន្ទុកកូនក្តីខ្ញុំ។

លោក នួន ជា បានធ្វើការជំទាស់ដោយតុលាការមិនអាចយកឯកសារថតចម្លងណាមួយមកជំនុំជម្រះជាផ្លូវការនោះបានទេ លើកលែងតែមានទឡ្ហីករណ៍ណាមួយជាក់លាក់បញ្ជាក់ថា ជាឯកសារដើមនោះទើបតុលាការទទួលយកបាន។ ដោយនៅថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ និងមុននោះទៅទៀតមានកងទ័ពវៀតណាមបានធ្វើអន្តរាគមន៍ និងចូលមកប្រយុទ្ធយ៉ាងខ្លាំងក្លា តទល់នឹងបក្សកុម្មុយនីស្តកម្ពុជាពេលនោះបក្សកុម្មុយនីស្តកម្ពុជា ហើយយើងទាំងអស់គ្នាមិនបានដឹងច្បាស់ទេ ថាតើជនបរទេសនេះបានប្រឌិតអ្វីខ្លះពីពេលនោះមក រហូតដល់ពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។

តាំងពីពេលដែលលោក នួន ជា បានជំទាស់រួចមកហើយ តាំងពីពេលបើកសវនាការករណី០០២ មកតើព្រះរាជអាជ្ញានៅតែយកឯកសារទាំងនេះមក ប្រើចំពោះមុខតុលាការដដែលៗ ដើម្បីធ្វើឲ្យឯកសារនេះទៅជាផ្លូវការក្នុងតុលាការ។ មិនតែប៉ុណ្ណោះ ឯកសារទាំងឡាយណាដែលមានបរិបទប្រហាក់ប្រហែលគ្នា ដែលសហព្រះរាជអាជ្ញាបានលើកយកដើម្បីដាក់បន្ទុកកូនក្តីខ្ញុំ គឺលោក នួន ជា នោះយើងក្រុមមេធាវីការពារ នួន ជា សូមធ្វើការជំទាស់យ៉ាងខ្លាំងក្លាចំពោះឯកសារទាំងឡាយណាដែលពុំមានឯកសារដើមមកប្រើចំពោះមុខអង្គសវនាការនៅពេលនេះ។

[១១:២២:៤១]

បើអង្គសវនាការនៅពេលនេះត្រូវការឲ្យយើងខ្ញុំដាក់បណ្តឹងជាលាយលក្ខណ៍អក្សរ យើងខ្ញុំនឹងធ្វើតាម ហើយបើតុលាការសាលាដំបូងបដិសេធការជំទាស់របស់យើងខ្ញុំនោះ យើងខ្ញុំមេធាវីការពារលោក នួន ជា នឹងប្តឹងឧទ្ធរណ៍ទៅតុលាការកំពូលក្នុងរឿងនេះទៀត។

ចំពោះសៀវភៅសរសេរអំពីកម្ពុជាប្រជាធិបតេយ្យ ដោយអ្នកនិពន្ធដែលមានចែងក្នុងឯកសារដែលយកមកជជែកគ្នាពេលនេះ ព្រមទាំងឯកសារកាសែតនានា ដែលព្រះរាជអាជ្ញាបានយកមកដាក់ក្នុងតុលាការសម្រាប់ចោទប្រកាន់ ដាក់បន្ទុកកូនក្តីខ្ញុំនោះ។ ក្រុមមេធាវីការពារលោក នួន ជា សុំឲ្យអ្នកនិពន្ធទាំងនោះមកធ្វើសក្ខីកម្មចំពោះតុលាការសាលាដំបូងនៅពេលនេះជាដាច់ខាត។ បើមិនដូច្នេះទេ នោះសវនាការអស់រយៈពេលយូរមកហើយ រហូតដល់ពេលនេះ ការដាក់បន្ទុករបស់សហព្រះរាជអាជ្ញាទាំងអស់សុទ្ធតែជាការចោទប្រកាន់យ៉ាងបែបស្រមោលៗ ពុំមានអ្វីជាក់លាក់ច្បាស់លាស់នោះទេ ហើយការចោទប្រកាន់កូនក្តីខ្ញុំ នួន ជា ជាការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរមកលើកូនក្តីរបស់ខ្ញុំរួចមកហើយ កំពុងរំលោភ និងរំលោភសិទ្ធិបន្តទៅទៀត។

[១១:២៤:១៣]

ដូចខ្ញុំបានជម្រាបមកខាងលើនេះ សូមតុលាការមេត្តាពិចារណា និងទាត់ចោលការចោទប្រកាន់ដែលព្រះរាជអាជ្ញាបានលើកមកជជែកដើម្បីដាក់ជូនតុលាការសម្រាប់សវនាការទាំងអស់នេះ។

ខ្ញុំជំទាស់នៅក្នុងឯកសារមួយនេះ ប៉ុន្តែបើយោង ហើយនិងស្តាប់ព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបាន ធ្វើអត្ថាធិប្បាយរួចមកហើយនេះ ខ្ញុំយល់ថាឯកសារទាំងក្រោមទាំងអស់ ក៏ប្រហាក់ប្រហែលគ្នាអ៊ីចឹងដែរ។

ខ្ញុំសូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការ អស់លោក លោកស្រីទាំងអស់គ្នា! ខ្ញុំសូមចាប់ផ្តើមដោយលើកយោបល់បឋមរបស់ខ្ញុំ ដោយសារតែខ្ញុំគិតថាវាមានលក្ខណៈចាំបាច់ក្នុងការចងចាំថា ក្នុងអំឡុងពេលកាលពីម្សិលមិញ និងថ្ងៃនេះ គឺសហព្រះរាជអាជ្ញាបានចាប់ផ្តើមក្នុងឱកាសមួយចំនួន នៅពេលដែលគាត់លើកបញ្ហានេះគឺគាត់ព្យាយាមធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលការពិភាក្សាទៅហើយរបៀបដែលគាត់ធ្វើដូច្នេះ គឺគាត់បានបង្ហាញឯកសារថាមានសរសេរអ្វីខ្លះ ហើយបន្ទាប់ពីហ្នឹងទៅ គឺថាគាត់បានលើកឡើងថាវាពាក់ព័ន្ធយ៉ាងម៉េចទៅនឹងហេតុការណ៍និងដីកាដែលមានចែង និងចំណុចដែលមាន -- អង្គហេតុដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពាក់ព័ន្ធយ៉ាងម៉េចទៅនឹងជនជាប់ចោទ?

[១១:២៦:០២]

ដូច្នេះហើយខ្ញុំសូមលើកជាយោបល់ឱ្យអង្គជំនុំជម្រះថា តើដំណើរការយ៉ាងម៉េចនៅក្នុងពេលសវនាការនេះ ហើយវាជាកាតព្វកិច្ចរបស់ខ្ញុំត្រូវចង្អុលបញ្ជាក់អំពីការផ្តល់យោបល់បែបនេះរបស់សហព្រះរាជអាជ្ញា។ អ្វីដែលលើកឡើងនៅពេលនេះវាមិនមែនជាភស្តុតាងនោះទេ ដូច្នេះហើយអ្វីដែលលើកឡើងនេះមិនមានតម្លៃ ឬក៏មិនមានទម្ងន់ណាមួយដែលអង្គជំនុំជម្រះត្រូវផ្តល់ជូននោះទេ។ សហព្រះរាជអាជ្ញានោះគឺថា ប្រសិនបើចង់ផ្តល់ជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅពេលនេះនោះ គឺថាអង្គជំនុំជម្រះគួរតែមានការប្រុងប្រយ័ត្ន ហើយគួរតែកំណត់ពេលវេលាឱ្យបានច្បាស់លាស់ ថារយៈពេលប៉ុន្មានដែលសហព្រះរាជអាជ្ញាគួរតែលើកឡើងសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់ខ្លួននៅក្នុងដំណាក់កាលក្រោយ។

តាមចំណុចនេះហើយ កាលពីម្សិលមិញគឺថា ខ្ញុំបានលើកមតិយោបល់របស់ខ្ញុំទូទៅពាក់ព័ន្ធទៅនឹងប្រភេទឯកសារទាំងអស់នេះ។ ខ្ញុំសូមលើកឡើងសាជាថ្មី កាលពីម្សិលមិញ និងនៅក្នុងរសៀលនេះគឺថាខ្ញុំក៏លើកចំណុចលម្អិតអំពីឯកសារ៥៤ ឬក៏៥៦ ដែលយើងបានលើកឡើង ហើយមិនទាន់បានជម្រាបជូន។ ហើយខ្ញុំដឹងថាអង្គជំនុំជម្រះគួរតែផ្តល់ពេលវេលាឱ្យខ្ញុំមួយចំនួនក្នុងការបង្ហាញឯកសារនេះ។

ខ្ញុំប្រហែលជាត្រូវការ២០នាទី ទៅ ៣០នាទី។

[១១:២៧:២៣]

ជំហររបស់ខ្ញុំត្រង់ឯកសារដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានោះគឺថា ឯកសារភស្តុតាងទាំងឡាយដែលបានលើកឡើងនោះ គឺត្រូវទទួលយក ប៉ុន្តែដោយមានឧបញ្ញត្តិព្យួរមួយចំនួន។ គឺត្រូវតែពិចារណាទៅលើភាពអាចទុកចិត្តបាននិងយថាភាពនៃឯកសារទាំងអស់នោះ។ ឯកសារភស្តុតាងទាំងអស់នោះគួរតែដាក់បញ្ចូលតាមរយៈសាក្សីដែលមកផ្តល់សក្ខីកម្ម គឺដោយធ្វើយ៉ាងណាឲ្យសាក្សីនេះគាត់ដឹងអំពីខ្លឹមសារ ហើយអាចឲ្យយើងផ្ទៀងផ្ទាត់ទៅបានទៅលើប្រភព និងភាពទុកចិត្តបាន។ ហើយប្រសិនបើភស្តុតាងឯកសារទាំងឡាយណាដែលមិនបានដាក់ជូនដោយមិនមានខ្សែសង្វាក់នៃអ្នករក្សាទុកឯកសារទាំងអស់នេះឲ្យបានត្រឹមត្រូវនោះយើងខ្ញុំសូមជំទាស់។

យើងដឹងហើយថានៅក្នុងប្រព័ន្ធស៊ីវិល មិនមែនថាយើងអាចទទួលយកគ្រប់ឯកសារទាំងអស់នោះទេ ហើយយើងត្រូវផ្អែកទៅលើទំនៀមទម្លាប់ច្បាប់ផងដែរ គឺបានន័យថានៅដំណាក់កាលចុងក្រោយនៃសវនាការនេះ គឺថាត្រូវពិនិត្យឯកសារឡើងវិញ ដើម្បីផ្តល់ទម្ងន់ ហើយយើងត្រូវតែពិចារណាទៅលើទម្ងន់ប៉ុនណាដែលគួរទៅ -- គួរផ្តល់ទៅដល់ឯកសារភស្តុតាងទាំងអស់នេះនៅពេលដែលមិនរក -- រកមិនឃើញប្រភពនៃឯកសារ និងភាពទុកចិត្តបាននៃឯកសារ។ ទាំងអស់នេះហើយគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់តែប៉ុណ្ណោះដល់អង្គជំនុំជម្រះ។

ហើយខ្ញុំសូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំធ្វើការឆ្លើយតបទៅនឹងឯកសារទាំងអស់នេះ។ ហើយយើងខ្ញុំក៏ថ្លែងអំណរគុណចំពោះសហព្រះរាជអាជ្ញាផងដែរ ដែលបានផ្តៀតឱកាសបង្ហាញនូវឯកសារទាំងអស់នេះ។ សូមអរគុណ។

[១១:២៨:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព ហើយនិងភាគីទាំងអស់ជាទីគោរព! ខ្ញុំនិយាយដោយខ្លីទេ ព្រោះថាខ្ញុំត្រូវតែនិយាយថា ខ្ញុំហាក់ដូចជាវង្វេងវង្វាន់អស់ហើយ ព្រោះថារហូតដល់ពេលនេះគឺថា បើខ្ញុំយល់ដំណើរការសវនាការនេះមិនខុសទេនោះ គឺថា

ដោយយោងទៅនឹងសារណាមួយចំនួននោះ ឥឡូវខ្ញុំសូមយោងទៅឯកសារ E170 កថាខណ្ឌ២ និង៤ ហើយនិងសារណា ២៣៣ ហើយកថាខណ្ឌ៣ ហើយនិងអនុស្សរណៈ២២៣ កថាខណ្ឌ៤។ បើសិនជាខ្ញុំយល់មិនខុសនោះទេ យើងបានធ្វើសវនាការ -- យើងធ្វើសវនាការមួយដើម្បីធ្វើការជំទាស់ទៅលើភាពទទួលយកបាននៃឯកសារ។ ហើយថ្ងៃនេះយើងកំពុងតែឃើញថា យើងកំពុងតែបង្ហាញឯកសារដោយភាគីមួយចំនួន ហើយរហូតដល់ពេលនេះគឺថា ចំពោះតុលាការហ្នឹង យើងត្រូវបង្ហាញឯកសារទៅសាធារណជន ហើយនិងផ្តល់លទ្ធភាពឲ្យភាគីតវ៉ា ហើយនិងឆ្លើយតប។ ខ្ញុំសូមកត់សម្គាល់ថាយើងផ្តល់លទ្ធភាពឲ្យជនជាប់ចោទធ្វើការអត្ថាធិប្បាយ។ ហើយនេះជាការបំភ្លឺនៅក្នុងអនុស្សរណៈទាំងអស់នេះដែលបញ្ជាក់អំពីដំណើរការសវនាការនេះ។

[១១:៣០:៣៩]

ក្នុងលក្ខខណ្ឌនេះ ក្រុម ខៀវ សំផន មិនទាន់បានត្រៀមខ្លួនក្នុងការតវ៉ា ទាក់ទងនឹងការបង្ហាញឯកសារគន្លឹះ ហើយនិងលើសារធាតុផងដែរ។ ដូចម្សិលមិញអ៊ីចឹង គឺថាខ្ញុំយល់ឃើញថាដោយសារយើងនិយាយអំពីការទទួលភាពទទួលយកបាននូវឯកសារយ៉ាងច្រើននោះ ហើយឥឡូវនេះយើងមិនត្រូវនិយាយមិនច្បាស់លាស់លើឯកសារនោះទេ ពីព្រោះឯកសារច្រើនណាស់។ អ្វីដែលខ្ញុំចង់និយាយថ្ងៃនេះគឺថាខ្ញុំចង់ជម្រាបជូនថា ដោយសារយើងមានអនុស្សរណៈជាច្រើននេះ ហើយនិងមានឯកសារគន្លឹះមួយចំនួននេះខ្ញុំសូមគាំទ្រលោក ម៉ែខល កាណាវាស ដែលនិយាយថា៖ នៅថ្ងៃនេះសហព្រះរាជអាជ្ញាក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយខាងការពារក្តីផងដែរ យើងមិនអាចនិយាយអំពី តវ៉ាអ្វីទាំងអស់លើឯកសារទេ។ ហើយយ៉ាងហោចណាស់ គឺថាឯកសារដែលយើងបានពិភាក្សាថ្ងៃនេះ ឬក៏យើងមិនទាន់បានពិភាក្សានោះ តាមការចង្អុលបង្ហាញរបស់តុលាការ យើងត្រូវតែត្រឡប់មកនិយាយអំពីឯកសារនេះនៅថ្ងៃក្រោយ។

ចំណុចមួយទៀត គឺថាដោយហេតុថាកូនក្តីខ្ញុំនៅមន្ទីរពេទ្យ អ៊ីចឹងយើងមិនមានមតិយោបល់អ្វីទេ អត់មានពាក្យសម្តីអ្វីនិយាយទេលោកប្រធាន ហើយសូមអរគុណ សូមបញ្ចប់ត្រឹមនេះ។

[១១:៣២:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងសេចក្តីជំទាស់នានាដែលធ្វើឡើងមេធាវីការពារក្តី។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ខ្ញុំមិនយល់ថាហេតុអ្វីបានជាមេធាវីការពារក្តីលោក ខៀវ សំផន ដែលគាត់យល់មិនបានច្បាស់នូវឯកសារដែលយើងខ្ញុំបានបង្ហាញនេះ មិនមែនជាទឡ្ហីករណ៍បញ្ចប់នៃការសួរដេញដោលនៅឡើយនោះទេ មិនមែនជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះទេ។ មេធាវីការពារក្តីគួរតែកត់សម្គាល់ទៅលើ និយាយអំពីការពិភាក្សាទៅលើការទទួលយកឯកសារទាំងនេះ។ ដូច្នេះ គួរណាស់តែធ្វើការកត់សម្គាល់ទៅលើឯកសារទាំងអស់នេះសិន។

[១១:៣៣:១៤]

ទាក់ទងទៅនឹងមេធាវីការពារក្តីលោក នួន ជា គឺផ្តោតទៅលើឯកសារ E3/5 ចុះថ្ងៃសីហា ឆ្នាំ ១៩៧៥ ជាឯកសារទង់បដិវត្ត។ ឯកសារនេះគឺថា គឺគាត់បានទាមទារឲ្យបង្ហាញឯកសារដើម។ មេធាវីការពារក្តីនូវតែទាមទារឲ្យបង្ហាញនូវទម្រង់នៃឯកសារ។ ដូច្នេះ ខ្ញុំធ្វើការកត់សម្គាល់បីចំណុចដូចខាងក្រោម ខ្ញុំរីករាយដែលថាសេចក្តីថ្លែងការណ៍របស់ នួន ជា នៅដើមដំបូងនៃសវនាការទាក់ទងទៅនឹងឯកសារមួយនេះ គឺទង់បដិវត្តនេះ។

ទី១ គឺជាឯកសារជាពណ៌នោះ ជាកូល័របានបង្ហាញហើយ ថានេះគឺជាសៀវភៅទង់បដិវត្ត ដែលគេបានថតចម្លងទៅជាឯកសារស-ខ្មៅ។ កូនសៀវភៅនេះគឺថាបានបង្ហាញចេញពីឯកសារទង់បដិវត្តពណ៌ដើម គឺជាពណ៌កូល័រ។ ទាក់ទងទៅនឹងការអះអាងថា ពេលខ្លះគឺថាយើងមិនបានស្វែងរកនូវការពិតដែលឯកសារនេះអាចយកមកធ្វើការកែប្រែ ដែលធ្វើឲ្យតុលាការនេះក្លាយទៅជា គ្រាន់តែជាតុលាការថ្កុកល្ហេនមួយនោះ។

[១១:៣៤:៤៦]

ដូច្នេះខ្ញុំសូមរំឭកថា អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី គីម វឿន រួចមកហើយអំពីទង់បដិវត្តនេះ។ គាត់បានផ្តល់សក្ខីកម្ម គាត់បានមើលទៅលើឯកសារហ្នឹង ហើយគាត់អះអាងអំពីយថាភាពរបស់ឯកសារទង់បដិវត្តនេះហើយ។ ហើយទាក់ទងទៅនឹងឯកសារចុះខែសីហា ៧៥ ដែលទង់បដិវត្តហ្នឹងនិយាយពីសុន្ទរកថា ដែលបានថ្លែងទៅកាន់កម្មាភិបាល២ ទៅ៣ពាន់នាក់នៅក្នុងខែកក្កដា ឆ្នាំ៧៥។ យើងបានស្តាប់សក្ខីកម្មរបស់កងទ័ពម្នាក់ដែលបានចូលរួមនៅក្នុងសន្និបាតនោះ ដែលថាបានស្តាប់ឮគេ

យកទង់បដិវត្តនេះយកមកបង្ហាញ។ ដូច្នេះ ការដែលមេធាវីការពារក្តីលើកឡើងពាក់ព័ន្ធទៅនឹងចំណោទបញ្ហាណាមួយទៅនឹងឯកសារនេះ គឺជាការមិនត្រឹមត្រូវទាល់តែសោះ។ បាទ នេះគឺជាចម្លើយរបស់ខ្ញុំទៅនឹងចម្លើយរបស់មេធាវីការពារក្តីនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

[១១:៣៦:១៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៨:១០]

**ប្រធានអង្គជំនុំ៖**

បាទ តាមកាលវិភាគដែលយើងបានឯកភាពគ្នាក្នុងការរៀបចំដំណើរការធ្វើសវនាការលើឯកសារនេះកាលពីម្សិលមិញ គឺនៅរសៀលនេះ អង្គជំនុំជម្រះនឹងស្តាប់នូវការបង្ហាញនូវការដាក់ឯកសាររបស់មេធាវីការពារក្តីលោក អៀង សារី ដែលមានចំនួន ៥៦ឯកសារ។

អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ថាតើការដែលសំណើសុំនេះហើយក្រុមមេធាវីបានរៀបចំរួចរាល់ហើយឬនៅ? ហើយអាចដំណើរការបានទេនៅរសៀលនេះ?

**លោក ម៉ៃខល កាណាវាស៖**

យើងខ្ញុំត្រៀមខ្លួនរួចហើយលោកប្រធានលោក អាចបង្ហាញបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុះខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីវិញ ដែលអំមិញបានលើកឡើងអំពីការមិនបានរៀបចំនៅឡើយ នូវការដាក់បង្ហាញ ឬក៏ការធ្វើអត្ថាធិប្បាយពាក់ព័ន្ធនឹងឯកសារអង្គហេតុ រចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ តើនៅរសៀលនេះអាចបង្ហាញបានដែរឬទេ?

[១១:៣៩:៣៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ជាថ្មីម្តងទៀត គឺថាយើងសោកស្តាយណាស់ដែលថា ការត្រៀមលក្ខណៈខ្លួនយើងនេះ គឺថាវាប្រញាប់ពេកដោយសារការធ្វើសវនាការនេះបន្ទាន់បន្ទំ ដោយសារយើងគិតថា យើង

ត្រូវធ្វើបង្ហាញបន្ទាប់ពីសហព្រះរាជអាជ្ញា នៅពេលព្រះរាជអាជ្ញាបង្ហាញទាំងអស់ហើយ បានយើងធ្វើ។ ក៏ប៉ុន្តែទាក់ទងនឹងការបង្ហាញឯកសារ ទាក់ទងនឹងរចនាសម្ព័ន្ធយោធា យើងអាចបង្ហាញនៅពាក់កណ្ដាលរសៀលនេះ បើសិនជាអង្គជំនុំជម្រះអនុញ្ញាតឲ្យយើងធ្វើក្រោយពីក្រុមមេធាវីលោក អៀង សារី ហើយយើងមានបញ្ជីឯកសារទាំងអស់។ ហើយយើងផ្ដល់បញ្ជីនេះទៅភាគីទាំងអស់ ហើយយើងមានឯកសារតិចនោះទេលោកប្រធាន។ ហើយនៅពេលបាយថ្ងៃត្រង់នេះ យើងផ្ដល់បញ្ជីនេះទៅឲ្យភាគី។

ហើយមួយទៀត បើយើងបង្ហាញឯកសារផ្សេងៗទៀតនោះ គឺថាយើងនឹងបង្ហាញក្រោយពេលដែលសហព្រះរាជអាជ្ញាធ្វើចប់ហើយ។ ហើយយើងត្រូវការពេលវេលាសមស្រប។ ក្នុងករណីទាំងពីរនេះយើងអាចធ្វើបានលោកប្រធាន។ ជួនយើងចាំឲ្យសហព្រះរាជអាជ្ញាបង្ហាញចប់ទាំងអស់ ហើយយើងបង្ហាញឯកសារផ្សេងៗដែលត្រូវបង្ហាញ។ ហើយរសៀលនេះ យើងបង្ហាញតែ ទាក់ទងនឹងរចនាសម្ព័ន្ធយោធាទេ លោកប្រធាន ក្រោយក្រុមមេធាវីលោក អៀង សារី។

[១១:៤០:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកថ្ងៃត្រង់ហើយ ដោយសារពេលវេលាខ្លីដែរដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៣ នាទី ដល់ម៉ោង ១៣:៤២ នាទី)*

[១៣:៤២:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការលើការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ របស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី ដែលពាក់ព័ន្ធទៅនឹងអង្គហេតុរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ ការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទី២ ហើយនិងទីកន្លែងសម្លាប់នៅទួលពោធិ៍ជ្រៃ ដែលសំណើសុំរបស់ក្រុមមេធាវីការពារក្ដីថាមានទាំងអស់៥៦ឯកសារ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ។

លោកមេធាវីកុំអាលសិន មានការលើកឡើងអំពីក្រុមតំណាងសហព្រះរាជអាជ្ញា គេចង់មានយោបល់អី? លោក កាណាវាស អាចអង្គុយចុះសិនបាន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៤៣:៣៣]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាងឈេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រមនិងភាគីទាំងអស់។ មុនពេលមេធាវីការពារក្ដី អៀង សារី លើកឡើងអំពីការជំទាស់ទៅលើបញ្ជីឯកសារ៥៤ដែលបានបញ្ជូនទៅនោះ ប្រសិនបើអាច ខ្ញុំសូមកាត់បន្ថយចំនួនឯកសារនៅក្នុងបញ្ជីនោះ ពីព្រោះថាបើតាមយើងនោះ ២៤នោះត្រូវបានជជែកពិភាក្សាគ្នារួចមកហើយ ហើយក៏ទទួលបានការសម្រេចពីអង្គជំនុំជម្រះរួចមកហើយ។ ដូច្នេះដើម្បីកុំឱ្យខាតពេលវេលា ហើយនិងជជែកពិភាក្សាទៅលើឯកសារដដែលនោះ ហើយនិងក៏មានឯកសារ១២ជាង ដែលត្រូវបានពិភាក្សាកាលពីម្សិលមិញនៅពេលរសៀលក៏ដូចជាឯកសារមួយចំនួនទៀតដែលត្រូវបានពិភាក្សាកាលពីឆ្នាំ២០០០ (ស៊ីក) រួចមកហើយនោះ ខ្ញុំសូមចំណាយពេល៥ ទៅ១០ នាទីដើម្បីផ្ដល់នូវបញ្ជីមួយ ហើយនិងផ្ដល់អំពីមូលហេតុ។ ដូច្នេះសូមអង្គជំនុំជម្រះមេត្តាសម្រេចថា តើយើងគួរកម្រិតការពិភាក្សាគ្នានៅរសៀលនេះត្រឹមតែលើឯកសារតែ៣០បានហើយ ពីព្រោះថាឯកសារផ្សេងៗនោះ គឺថាបានពិភាក្សារួចមកហើយ ហើយឯកសារ៣០នេះ គឺថាមាននៅក្នុងកំណត់សម្គាល់ជើងទំព័រនៃដីកាដំណោះស្រាយ។ ដូច្នេះមិនគួរពិភាក្សាទៅលើឯកសារផ្សេងទៀតហើយជំទាស់នោះទេ ពីព្រោះថាយើងបានពិភាក្សារួចមកហើយ គឺនៅសល់តែឯកសារ៣០ ប៉ុណ្ណោះដែលថាមិនទាន់បានទទួលការពិភាក្សាជំទាស់នោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវ៉ាស!

[១៣:៤៥:៣១]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។

ជាដំបូងខ្ញុំមិនមានចេតនាដើម្បីលើកយកគ្រប់ឯកសារទាំងអស់ ដូចដែលខាងព្រះរាជអាជ្ញាបានបញ្ជាក់នោះទេ។ គោលជំហររបស់យើង គឺថាយើងនឹងផ្ដោតទៅលើប្រធានបទនីមួយៗ។ ចំណុចទី២ ឯកសារទាំង៥៤ ដែលយើងគ្រោងនឹងពិភាក្សាដែលជាផ្នែកឧសម្ព័ន្ធ ហើយយើងបានដាក់ទៅអង្គជំនុំជម្រះជាសារណារលាយលក្ខណ៍អក្សរហ្នឹង គឺរួមបញ្ចូលទាំងឯកសារដែលយើងបានកត់សម្គាល់នៅជើងទំព័រផងដែរ ហើយនៅពេលដែលយើងពិនិត្យមើលទៅលើអនុស្សរណៈ E223/2 នៅកថាខណ្ឌលេខ៥ គឺហាក់ដូចជាមានការមិនបញ្ជាក់អំពីឯកសារ ដែលនិយាយអំពីរចនាសម្ព័ន្ធយោធានោះទេ ដូច្នេះហើយនេះគឺជាគោលដៅដែលយើងធ្វើដូច្នេះ។

[១៣:៤៦:២២]

ប្រហែលជាមានការជាន់គ្នា ដែលមិនអាចជៀសវាងបានទៅលើផ្នែកមួយចំនួន ប៉ុន្តែយើងយកឱកាសនេះ ដើម្បីមើលទៅលើជើងទំព័រតែម្ដង ហើយបានបង្ហាញនៅថ្ងៃនេះ មិនលើកឡើងពីការជំទាស់ទៅលើឯកសារនៃដីកាដំណោះស្រាយ IS5.3 ឬមួយក៏ ឬក៏ឯកសារ D125/2.17 នោះទេ។ ហើយបន្ថែមពីលើនេះទៀត យើងមិនលើកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីនោះដែរ។ ហើយតាមសំណើរបស់សហព្រះរាជអាជ្ញា ដែលមានលេខ E200.8 ក៏ដូចជាឯកសារមួយចំនួនផ្សេងទៀត យើងយល់ឃើញថា ឯកសារទាំងអស់នេះ គឺជាកម្មវត្ថុនៃសវនាការនៅពេលអនាគត។ ដូច្នេះខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថាប្រធានបទ ឬក៏ឯកសារមួយចំនួនគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលយើងបានឮកាលពីម្សិលមិញ។ ហើយខ្ញុំរីករាយដែលថា ខ្ញុំនឹងដាក់នូវឧបសម្ព័ន្ធរបស់យើង ដោយមានសារណាដែលមានឧបសម្ព័ន្ធរបស់យើង ហើយយើងអាចនឹងដាក់ជាលាយលក្ខណ៍អក្សរ ហើយយើងអង្គុយចុះ ដោយមិន -- កុំឲ្យខាតពេលវេលារបស់តុលាការ។

[១៣:៤៧:៤៦]

ប៉ុន្តែប្រធានបទដែលខ្ញុំមាននៅទីនេះ គឺនិយាយអំពីសារទូរលេខក៏ដូចជាលិខិតដែលខ្ញុំត្រូវការ

បញ្ជាក់បំភ្លឺជាមួយនឹងតុលាការ គឺលិខិតរបស់ ហេងឆ័រ ហើយក៏ជាលិខិតរបស់ ប៉ាស្ទ័រ ក៏ដូចជាចម្លើយមួយចំនួន ឬក៏ឯកសារមួយចំនួនរបស់ យូអេសអេអាយឌី, យូនីសេហ្វ, អង្គការសុខភាពពិភាពលោក ឬក៏ក្រសួងការបរទេសសហរដ្ឋអាមេរិក ឬក៏អង្គការមួយចំនួនទៀត។ ក្រៅពីនេះ ក៏មានកំណត់ហេតុអន្តរជាតិខាងអាមេរិក ឬក៏បារាំងដែលយើងបានធ្វើកាលពីម្សិលមិញរួចមកហើយ ហើយក៏មានប្រព័ន្ធសារព័ត៌មានរួមបញ្ចូលទាំងអត្ថបទសារព័ត៌មានដែលរួមមានអត្ថបទរបស់ សួង ស៊ីគឿន ផងដែរ។ យើងមិនជំទាស់ទៅនឹងឯកសារទាំងអស់នេះទេ។ វាហាក់ដូចជាជាន់នឹងអ្វីដែលគាត់បានផ្តល់សក្ខីកម្ម ប៉ុន្តែនេះគឺជាឆន្ទានុសិទ្ធិរបស់តុលាការ។

[១៣:៤៨:៥០]

ក្រៅពីនេះ មានឯកសារបោះពុម្ពរបស់បក្សកុម្មុយនីស្តកម្ពុជារួមដូចជា កំណត់ហេតុការប្រជុំ ក៏ដូចជាខ្សែវីដេអូ ដែលមានចំណងជើងថា “តើមានអ្វីកើតឡើងនៅប្រទេសកម្ពុជា?” ដែលជារឿងរបស់ រ៉ុមនីស្ទ៊ត ហើយក្រៅពីនេះមានការ -- សេចក្តីសម្រេចផ្ទេរសិទ្ធិអំណាចពីចៅក្រម យូ ប៊ុនឡេង ទៅចៅក្រម ឡឺម៉ុងដ៍ ដែលអនុញ្ញាតឲ្យចៅក្រម ឡឺម៉ុងដ៍ ធ្វើការចេញនូវដីកាចាត់ឲ្យស៊ើបជំនួសដោយលោក ហេងឆ័រ។ ដូច្នេះ ខ្ញុំគិតថា ខ្ញុំទុកជូនអង្គជំនុំជម្រះជាអ្នកសម្រេចថាតើខ្ញុំត្រូវធ្វើបទបង្ហាញ ឬមួយក៏ខ្ញុំត្រូវធ្វើយ៉ាងម៉េចទាក់ទងទៅនឹងការជំទាស់របស់យើង។ ហើយការជំទាស់របស់ខ្ញុំ គឺដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង គឺផ្អែកទៅលើវិធាន៧៣ -- គឺវិធាន៧៧(៣) ក៏ដូចជាយុត្តាធិការពេលវេលា។ ហើយម្យ៉ាងទៀតអ្វីដែលយើងនិយាយគឺវាពាក់ព័ន្ធទៅនឹងមូលដ្ឋាន ក៏ដូចជាបរិបទដែលយើងបានឃើញ ក៏ដូចជាយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះដែលមិនគួរទទួលយក។ ហើយចំពោះលិខិតរបស់ ហេងឆ័រ ខ្ញុំគិតថាគួរតែលើកឡើង ព្រោះថាជាលិខិតរបស់ហេងឆ័រ ផ្ញើទៅ ក.ស.ច.ស ក្នុងពេលដែលគាត់ផ្ញើទៅនេះ ដើម្បីពន្យល់នូវបញ្ហាមួយចំនួន។ ហើយក្នុងនោះ ក៏មានការសង្ខេបនៅលើការសម្ភាសរបស់ ហេងឆ័រ ជាមួយលោកស្រី អៀង ធីរិទ្ធ ហើយយើងមិនគួរទទួលយក ដោយសារតែវាមិនអាចពឹងផ្អែកបាន។ ហើយម្យ៉ាងវិញទៀត វាហាក់ដូចជាមានការវាយជាអក្សរនៅជើងទំព័រ។ ដូច្នេះ ខ្ញុំគិតថា វាមិនមានឯកសារ -- គឺជាឯកសារ E185.2។ ដូច្នេះ ខ្ញុំគិតថា ដើម្បីកុំឲ្យខាតពេលវេលាពាក់ព័ន្ធទៅនឹងឯកសារ យូ.អេស.អេ.អាយ.ឌី ក៏ដូចជាអង្គការ យូនីសេហ្វ និងអង្គការមួយចំនួនដែលខ្ញុំបានបញ្ជាក់នោះ។

[១៣:៥១:២៨]

ខ្ញុំគិតថា អង្គជំនុំជម្រះគួរផ្តល់នូវតម្លៃ ឬក៏ទម្ងន់បន្តិចបន្តួច ឬក៏មិនគួរឲ្យតម្លៃសោះ ដោយសារតែវាមិនអាចក្នុងការពិនិត្យទៅលើសុពលភាពនៃអ្វីដែលបានរាយការណ៍ ឬក៏ឯកសារដែលបានរាយការណ៍ ក៏ដូចជាព័ត៌មានដែលបាននិយាយនោះ វាមិនមែនជាការសង្កេតដោយផ្ទាល់នោះទេ។

ជារួមនេះ គឺជាអ្វីដែលខ្ញុំចង់លើកឡើង ហើយខ្ញុំគិតថា ខាងព្រះរាជអាជ្ញាហាក់ដូចជាចង់តវ៉ា ឬក៏ដូចជាមានបញ្ហាអ្វីដែលជាការលើកសង្កេតឡើងរបស់គាត់។ ដូច្នេះ ខ្ញុំសូមទុកឱកាសជូនគាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំបានធ្វើសំណើទៅអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះបានផ្តល់ឱកាសលោក កាណាវាស ឆ្លើយតប។ ខ្ញុំគិតថា ឲ្យគាត់ឆ្លើយតបទៅនឹងការស្នើរបស់ខ្ញុំសិន។ ហើយបន្ទាប់មកទៀត គឺថាអង្គជំនុំជម្រះជាអ្នកសម្រេច ដើម្បីអនុញ្ញាតឲ្យខ្ញុំបញ្ជាក់អំពីឯកសារណាខ្លះ ដែលមានភាពជាន់គ្នានោះ ឬក៏អាចធ្វើជាលាយលក្ខណ៍អក្សរនៅពេលក្រោយ ហើយនៅពេលក្រោយមកទៀត ទើបលោកមេធាវី កាណាវាស អាចធ្វើការជំទាស់បាន។ ដូច្នេះ ហាក់ដូចជាច្របូកច្របល់ហើយ ខ្ញុំនៅពេលនេះ។ ខ្ញុំមិនដឹងថា តើអង្គជំនុំជម្រះចង់ឲ្យខ្ញុំធ្វើបញ្ជីនៃឯកសារដែលបានពិភាក្សាគ្នារួចមកហើយមុន ឬក៏យ៉ាងម៉េច?

[១៣:៥៣:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ត្រឹមត្រូវហើយ ប្រសិនបើលោកជំទាស់ ថាឯកសារប៉ុន្មាន ដែលលោកគិតថាមិនចាំបាច់ឲ្យមេធាវីការពារក្តីលោក អៀង សារី ធ្វើបទបង្ហាញទេ ដោយមូលហេតុជាន់គ្នា។ លោកធ្វើបញ្ជីឲ្យបានច្បាស់លាស់មក ដើម្បីឲ្យភាគីម្ខាងទៀតស្តាប់យល់ អង្គជំនុំជម្រះក៏ស្តាប់យល់ដែរ ដើម្បីឈានដល់ការសម្រេចលើបញ្ហានេះ ឲ្យបានច្បាស់លាស់។ បើគ្រាន់តែលោក គ្រាន់តែនិយាយរួមៗ អ៊ីចឹង តើមានមូលដ្ឋានអី ដើម្បីសម្រេចនោះ? និយាយឲ្យច្បាស់លាស់សិនទៅ ២០ ឬក៏២៤ អីខ្លះដែលមានអត្តសញ្ញាណឯកសារ ដែលជាន់គ្នា ជាបញ្ជីមក ដើម្បីឲ្យគាត់ឆ្លើយតប ដោះស្រាយលើបញ្ហាជំទាស់នេះ ជាមុនសិនថាតើជំទាស់ហ្នឹងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ដើម្បីឲ្យខាងភាគីដែលត្រូវស្នើសុំបង្ហាញឯកសារហ្នឹងត្រូវបង្ហាញឯកសារទាំងមូល ទាំងតាមការស្នើសុំ ឬក៏បង្ហាញនៅក្នុងកម្រិតមួយដែលអង្គជំនុំជម្រះនឹង

សម្រេចតាមសំណើសុំរបស់លោក?

លោកគ្រាន់តែនិយាយជារួម ហើយអត់ដឹងថា ឯកសារណាខ្លះផង។

[១៣:៥៤:៣៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីធ្វើហើយ។ ខ្ញុំនឹងធ្វើតាមលំដាប់នៃតារាងដែលផ្តល់ជូនដោយខាងមេធាវីការពារក្តី។

ឯកសារទី១ នោះ ដំបូងនោះ គឺស្ថិតនៅក្នុងតារាងដែលបានផ្ញើតាមអ៊ីម៉ែលមកឲ្យយើងខ្ញុំ កាលពីព្រឹកមិញនោះ គឺឯកសារ D108/28.48។

ឯកសារនេះមានលេខ E3 ហើយ ដែលមាន E3/1750 ហើយឯកសារនេះ ត្រូវបានបង្ហាញជូនសាក្សីមួយចំនួនរួចហើយជាពិសេសដូចជាលោក មាស វឿន កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ដោយចៅក្រម ឡាវ៉ែន៍។ ហើយមានប្រតិចារឹកគឺ E1/131.1 ប្រហែលនៅម៉ោងដប់មួយ និងហាសិបនាទី ហើយនៅពេលនោះមិនមានការជំទាស់ទៅលើការបង្ហាញឯកសារនេះទេ។

[១៣:៥៥:៥៤]

ឯកសារទី២ ដែលបង្កនូវការលំបាកនោះគឺថា គឺនៅលេខរៀងទី៣ ដែលផ្តល់ជូនដោយមេធាវី អៀង សារី គឺឯកសារលេខ D108/31.28។ ឯកសារនេះគឺថាមាននៅក្នុងឯកសារមួយផ្សេងទៀតដែលត្រូវបានពិភាក្សាគ្នារួចមកហើយគឺឯកសារតែមួយទេ តែមានលេខកូដផ្សេងគឺឯកសារ D108/7.3។ ឯកសារនេះមានលេខ E3 រួចហើយ ដែលមាន E3/1049 ក្រោយពីការពិភាក្សាគ្នាកាលពីឆ្នាំមុននោះ។

បន្ទាប់មកទៀត ដូចខាងមេធាវីការពារក្តី អៀង សារី បានបញ្ជាក់ហើយមានសេចក្តីថ្លែងរបស់សាក្សីមួយចំនួន ហើយមានការធ្វើសវនាការផ្សេងៗគ្នានោះគឺឯកសារ D125/97។ ឯកសារនោះរបស់ TCW-231។

បន្ទាប់មកទៀតមានឯកសារ៤ ដែលត្រូវបានពិភាក្សាគ្នាកាលពីម្សិលមិញនៅក្នុងសវនាការនេះ គឺដែលមានចាប់ផ្តើមពី D199/26.2។ ហើយបន្ទាប់មកទៀតគឺឯកសារ D199/26.2.209 ដែលមាននៅក្នុងបញ្ជី ឧបសម្ព័ន្ធ២(ក) ដែលមានលេខ E223/2/1.2 ហើយស្ថិតនៅក្នុងលេខរៀងទី៧។ ដូច្នេះ យើងមិនចាំបាច់និយាយអំពីឯកសារអស់នេះទេ ពីព្រោះថា យើងនិយាយពីម្សិលមិញរួចមកហើយ។

[១៣:៥៧:៥៤]

ឯកសារមួយទៀតនោះគឺ D199/26.2.219 គឺដូចគ្នាដែរគឺមាននៅក្នុងបញ្ជីកាលពីម្សិលមិញ ដែលមានលេខរៀងទី៨។ បន្ទាប់មកទៀត D199/26.2.228 គឺដូចគ្នា យើងបានពិភាក្សាគ្នាកាលពីម្សិលមិញនៅពេលរសៀលរួចមកហើយ។ ឯកសារនេះមានលេខរៀងទី៩ នៅក្នុងបញ្ជីឧបសម្ព័ន្ធ២(ក) ដែលមានលេខ E223/2/1.2។ បន្ទាប់មកទៀតឯកសារ D199/26.2.256 ឯកសារនេះត្រូវបាន ពិភាក្សាគ្នាកាលពីម្សិលមិញមានលេខរៀងទី១១ នៅក្នុងបញ្ជីឧបសម្ព័ន្ធ២(ក)។

បន្ទាប់មកទៀតយើងមានឯកសារពីរផ្សេងទៀត គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី គឺ D232/65 គឺសាក្សី TCW-389។ បន្ទាប់មកទៀតគឺ D233/8 ដែលជាសាក្សី TCW-796 សាក្សីទាំងពីរនេះត្រូវបានស្តាប់ចម្លើយផ្សេងៗគ្នារួចមកហើយ។ ឯកសារមួយទៀតគឺ D269/9/1.16 ដែលស្ថិតនៅក្នុងលេខរៀងទី១៩ ដែលបានផ្តល់ជូនដោយមេធាវីការពារក្តីលោក អៀង សារី។ ឯកសារនេះមានលេខ E3/1765 ហើយក៏មានលេខកូដមួយផ្សេងទៀត E3/781 និង D366/7.1.157។ ឯកសារនេះ គឺមាននៅក្នុងបញ្ជីឯកសាររបស់យើងកាលពីខែកក្កដា ឆ្នាំ២០១១ គឺឯកសារ E109/4.1 នៅក្នុងឧសម្ព័ន្ធ ២ នៅលេខរៀងទី១៦ នៃឧសម្ព័ន្ធនេះ។ ឯកសារនេះត្រូវបានពិភាក្សាគ្នាកាលពីខែមករា ឆ្នាំ២០១២ ហើយឯកសារដែលមាននៅក្នុងបញ្ជីរបស់មេធាវីការពារក្តីគឺ D269/91.16 នោះគឺដូចគ្នាបេះបិទទៅនឹងឯកសារ D366/7.1.157 ហើយ E3 នោះត្រូវបានផ្តល់ជូនដោយអង្គជំនុំជម្រះរួចហើយក្រោយពីមានការសម្រេច លេខ E185 នៅខែមេសា ឆ្នាំ២០១២។

[១៤:០១:២៣]

នៅលេខទី២០ របស់លោក អៀង សារី នោះ គឺថាមានឯកសារលេខ D299.1.15R។ ឯកសារមួយនេះមានលេខកូដ E3 រួចហើយគឺ E3/3091R គឺ E3/3091R។ ឯកសារនេះមាននៅក្នុងបញ្ជីរបស់យើងកាលពីខែកក្កដា ឆ្នាំ២០១១ E109/4.1 លេខរៀងដប់ -- នៅលេខរៀងទី១៥០ ឧសម្ព័ន្ធ១៦។ អង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយផ្តល់លេខ E3 ហើយកាលពីខែមីនា ឆ្នាំ២០១២ ហើយដែលសេចក្តីសម្រេចនេះមានលេខ E185.1។

នៅលេខរៀងទី២៣ នៃបញ្ជីឯកសាររបស់លោក អៀង សារី មានលេខឯកសារ D304/1.3 ឯកសារនេះមាននៅក្នុងបញ្ជីខែកក្កដា ឆ្នាំ២០១១ នៅឧបសម្ព័ន្ធ១២ លេខរៀង៥៥៥។ នេះគឺជាសេចក្តីប្រកាសរបស់បុគ្គលម្នាក់ មិនមែននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះទេ ហើយឯកសារនេះត្រូវតែធ្វើការពិភាក្សានៅក្នុងសវនាការផ្សេង ដូចទៅក្នុង -- ដូចឯកសារដែលមាននៅក្នុងឧសម្ព័ន្ធ១២,

១៣ នៃបញ្ជីឯកសារកាលពីខែកក្កដា ឆ្នាំ២០១១ ហើយមានឯកសារប្រាំបីដែលត្រូវបានពិភាក្សាកាលពីម្សិលមិញ។

[១៤:០៣:១៩]

ខ្ញុំសូមត្រឹមតែអានលេខកូដ ហើយនិងលេខរៀងដែលមាននៅក្នុងបញ្ជី (ក) កាលពីយើងពិភាក្សាកាលពីម្សិលមិញ។ ឯកសារដំបូងគឺ D313/1.2.65។ ឯកសារនេះមាននៅក្នុងបញ្ជីកាលពីយើងពិភាក្សាកាលពីម្សិលមិញគឺ E223/2/1.2 នៅលេខរៀងទី១៣។

បន្ទាប់មកទៀតឯកសារ D365/1.1.10 ឯកសារនេះត្រូវបានពិភាក្សាកាលពីម្សិលមិញដែរ គឺនៅក្នុងឧសម្ព័ន្ធទី១ គឺ E223/2/1.1 នៅលេខរៀងទី១៨។ ឯកសារ D365/1.1.15 នៅក្នុងឧសម្ព័ន្ធ១ហ្នឹងដូចគ្នា គឺលេខរៀងទី១៩ ដែលបានពិភាក្សាគ្នាកាលពីម្សិលមិញរួចហើយ។ ឯកសារ D365/1/1.7 នៅក្នុងលេខរៀង២១ ដែលយើងបានពិភាក្សាកាលពីម្សិលមិញ។ ឯកសារ D365/1.1.23 ឯកសារនេះក៏មាននៅក្នុងឧបសម្ព័ន្ធដែលយើងបានពិភាក្សាគ្នាកាលពីម្សិលមិញ គឺលេខរៀងទី២៣ គឺឧបសម្ព័ន្ធមួយដែលមានលេខ E223/2/1.1, D365/1.1.28 មាននៅលេខរៀង២៦ នៃឧបសម្ព័ន្ធ១។ D365/1.1.3 លេខរៀងទី១៧ នៃឧបសម្ព័ន្ធដែលយើងបានពិភាក្សាគ្នាកាលពីម្សិលមិញ ហើយជាចុងក្រោយគឺ D365/1.1.34 នៅលេខរៀងទី២៧ នៃឧសម្ព័ន្ធ១ ហើយនិងមានឯកសារមួយចំនួនផ្សេងទៀតដែលត្រូវបានពិភាក្សាគ្នារួចមកហើយ។ ឯកសារដំបូងនោះគឺ កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានលេខ D369/6 ដែលយើងមិនទាន់បានពិភាក្សាគ្នាទេ ក៏ប៉ុន្តែត្រូវធ្វើសវនាការដាច់ដោយឡែកមួយ ហើយដែលមាននៅឧបសម្ព័ន្ធ១២ នៅលេខរៀង១៨៩ នៃឯកសារ E109/4.1។

ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងបញ្ជីដែលបានផ្តល់ជូនយើងនៅថ្ងៃនេះ គឺមេធាវីការពារក្តី អៀង សារី បានដកឯកសារមួយចេញគឺ D109 -- D108/9.1 ឬក៏ -- ហើយឯកសារនេះមិនស្ថិតនៅក្នុងបញ្ជីនៃឯកសារដែលយើងត្រូវពិភាក្សានៅរសៀលនេះទេ។

[១៤:០៦:៤៦]

ដូច្នេះនៅសល់បីទៀត ឯកសារដំបូងនោះគឺលេខ IS13.30 ដែលមានលេខ E3/800 ឯកសារនេះត្រូវបានពិភាក្សាគ្នានៅក្នុងសវនាការកាលពីឆ្នាំ២០១២ រួចមកហើយ។ ហើយវាមាននៅក្នុងបញ្ជីឯកសាររបស់យើងដែលយើងមានលេខ E109/4.1 គឺនៅឧបសម្ព័ន្ធ៣ លេខរៀងទី៤០។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលេខ E185 រួចមកហើយ។ ហើយបានបញ្ជាក់ថា ឯកសារនេះអាចទទួល

យកបាន។ ដូច្នេះអាចមានលេខកូដលេខ E3 រួចទៅហើយ ឯកសារនេះ។

ស្ថានភាពដូចគ្នាផងដែរសម្រាប់ឯកសារ IS13.1 ដែលមានលេខយោងមួយទៀតគឺ D248/6.1.5។ មានលេខ E3 រួចមកហើយ ឯកសារនេះគឺ E3/822។ ឯកសារនេះមាននៅក្នុងបញ្ជីរបស់យើងកាលពីខែកក្កដា ឆ្នាំ២០១១ គឺ E109/4.1 នៅឧបសម្ព័ន្ធ៣ លេខរៀង៤១ ហើយដែលមានលេខយោង D248/6.1.5 តាមពិតទៅឯកសារ IS13.31 ហើយនិងឯកសារ D248/1.5 នោះមានជាភាសាខ្មែរ ហើយនិងមានភាសាអង់គ្លេសខុសគ្នាមួយទំព័រនៅក្នុងការបកប្រែ។ នេះខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះ។

ហើយឯកសារចុងក្រោយមួយទៀតដែលត្រូវពិភាក្សាគ្នាដាច់ដោយឡែកនោះគឺ កំណត់ហេតុស្តាប់ចម្លើយសាក្សី TCW-325 ដែលមានលេខយោង IS19.71 ឬក៏លេខយោង D366/7.1.5870។ ឯកសារនេះស្ថិតនៅក្នុងឧបសម្ព័ន្ធ១២ លេខរៀង៤៨៨ នៃបញ្ជីឯកសារ E109/4.1 របស់ហើយ។ ប៉ុន្តែដូចជាខ្ញុំបានបញ្ជាក់ដែរថា ដូចកំណត់ហេតុផ្សេងទៀតដែរ ឯកសារនេះត្រូវពិភាក្សាគ្នានៅក្នុងសវនាការផ្សេងដាច់ដោយឡែក។ ទោះបីជាមានឯកសារច្រើនក៏ដោយ តែខ្ញុំគិតថាត្រូវតែមានសវនាការដាច់ដោយឡែក ដើម្បីពិភាក្សាទៅលើឯកសារប្រភេទនេះ។ សូមអរគុណលោកប្រធាន។

[១៤:០៩:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបញ្ហាអីទេអំមិញ? មានចង់មតិមានមតិយោបល់អីទេ?

សូមអញ្ជើញលោកខាងមេធាវីការពារក្តីពិភាក្សាគ្នាលើការសំណើសុំ និងហេតុផលនៃការស្នើសុំដកចេញនូវឯកសារមួយចំនួន ដោយសារមូលហេតុឯកសារនេះបានដាក់ជាន់គ្នា។

យ៉ាងម៉េចទៅ? អំមិញអញ្ជើញហើយ ផ្តល់វេទិកាទៅហើយ អត់ងើបឈរ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន អំមិញនេះខ្ញុំក្រោកឡើងបាត់ហើយ បើសិនជាលោកប្រធានអនុញ្ញាតនោះ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់ធ្វើការកត់សម្គាល់ជាបឋមមួយ ហើយនិងសុំការបំភ្លឺមុនពេលដែលសហភាតាការពារក្តីធ្វើការជំទាស់ដោយផ្ទាល់មាត់នោះ។ ពីព្រោះថាខ្ញុំមានអារម្មណ៍ថាហាក់ដូចជាគាត់យល់ឃើញថាជារឿងធម្មតាទេ ដែលក្នុងការដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរ។ ម្សិលមិញអង្គជំនុំជម្រះនិយាយ

ថានឹងផ្ដល់របៀបធ្វើទៅដល់ក្រុមមេធាវី ខៀវ សំផន, នួន ជា ពីព្រោះថាកូនក្ដីរបស់ពួកគាត់មិនមានវត្តមាន ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើការដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរដែរឬទេ? ពីព្រោះថាកាលណាអនុញ្ញាតឲ្យដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរហើយ គឺថាវាអាចប៉ះពាល់ ឬក៏ធ្វើឲ្យមានការប្រែប្រួលទៅដល់ការពិភាក្សាដោយផ្ទាល់មាត់យើងនៅក្នុងសាលសវនាការនេះលោកប្រធាន។

[១៤:១១:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ! សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថាសហព្រះរាជអាជ្ញាមានបញ្ជីឯកសារកាលពីម្សិលមិញហើយគឺគាត់មិនមានការតវ៉ានៅពេលដែលលើកឡើងនៅម្សិលមិញនោះទេ។ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹងវាអាចមានឯកសារជាន់គ្នា។ ដូច្នេះហើយ យើងខ្ញុំត្រូវលើកឡើងអំពីកថាខណ្ឌទាំងឡាយដែលវាចែងអំពីចំណុចទាំងអស់នេះ។ ហើយខ្ញុំនឹងព្យាយាមប្រុងប្រយ័ត្នលើកឡើងដោយខ្លី និងលម្អិតតាមដែលអាចធ្វើទៅបាន ហើយធ្វើយ៉ាងណាឲ្យឯកសារនេះអាចឲ្យយើងទទួលយកបាន។

[១៤:១២:៣៤]

ឯកសារដែលយើងបានដាក់បញ្ចូលនៅក្នុងបទបង្ហាញនេះ ខ្ញុំសូមលើកឡើងថាមិនមែនជាលេសទេ គឺវាធ្វើឡើងដោយប្រញាប់។ ដូច្នេះ យើងឃើញថាវាប្រាកដជាមានឯកសារជាន់គ្នាមែន យើងខ្ញុំសូមអធ្យាស្រ័យ។ ទោះបីជាយ៉ាងនេះក្ដី យើងខ្ញុំសូមលើកឡើងថា បទបង្ហាញរបស់យើងផ្អែកទៅតាមប្រធានបទនីមួយៗ។ ជាការពិតនៅក្នុងពេលអនាគត ប្រសិនបើសហព្រះរាជអាជ្ញា ជាពិសេសសហព្រះរាជអាជ្ញាមួយនេះ គឺមានបញ្ហាពេលវេលានោះ គឺថាគឺគួរតែពិនិត្យមើលឯកសារណាខ្លះដែលយើងដាក់បញ្ចូលខុស ហើយគួរតែប្រាប់យើងខ្ញុំមកវិញ ហើយយើងខ្ញុំនឹងរីករាយណាស់មើលទៅលើឯកសារខុស ដើម្បីកុំឲ្យវាខាតបង់ពេលវេលា យើងទាំងអស់គ្នា។

ដើមបណ្ដឹងរដ្ឋប្បវេណីកាលម្សិលមិញ លោកស្រីក៏នៅទីនេះដែរ ខ្ញុំឃើញគាត់អង្គុយនៅទីហ្នឹង។ ខ្ញុំឃើញគាត់នៅអង្គុយនៅទីនេះ ពាក់ព័ន្ធទៅនឹងពេលដែលខ្ញុំលើកឡើងអំពីសារណាជាលាយលក្ខណ៍អក្សរ ហើយកាលពីអតីតកាលនោះ គឺថាខ្ញុំក៏បានលើកឡើងអំពីសារណាជាលាយលក្ខណ៍អក្សរដែរ

ហើយគាត់នោះមិនបានលើកឡើងជំទាស់ទៅលើចំណុចនេះទេ ហើយខ្ញុំដឹងថាគាត់ប្រាកដជាបានស្តាប់ឮសារណារបស់ខ្ញុំកាលពីម្សិលមិញ ហើយគឺៗគាត់អាចសុំបញ្ជាក់បានទៅលើចំណុចនេះ។

[១៤:១៣:៥៩]

យើងខ្ញុំសូមលើកឡើងថា កាលពីអតីតកាល យើងខ្ញុំបានដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារផងដែរ បន្ថែមទៅលើការបង្ហាញដោយផ្ទាល់មាត់។ អង្គជំនុំជម្រះសាលាដំបូងមិនមានបំណងទទួលយកសារណាជាលាយលក្ខណ៍អក្សរនោះ នៅពេលនោះគឺថាយើងអាចសុំឱ្យមានការណែនាំពីអង្គជំនុំជម្រះ នៅពេលដែលបដិសេធមិនយកសារណាជាលាយលក្ខណ៍អក្សរ។ ហើយជាពិសេសចំពោះឯកសារទាំងឡាយដែលយើងបានដូរពីលេខកូដ E មក D ដែលពេលខ្លះទៅ វាធ្វើឱ្យយើងនោះបាត់ដាន ឬក៏វាធ្វើឱ្យភាគីមានការព្រួយបារម្ភ ដែលត្រូវដាក់សារណាជាលាយលក្ខណ៍អក្សរជាពិសេសទៅលើប្រធានបទមួយចំនួនដែលចាំបាច់។

ខ្ញុំសូមបន្ថែមថា នេះគឺជាទម្លាប់ដែលយើងប្រើប្រាស់នៅតាមសាលាក្តីអន្តរជាតិនានាដែលកំពុងជំនុំជម្រះលើឧក្រិដ្ឋកម្មសង្គ្រាម។ យើងខ្ញុំសន្និដ្ឋានដូចដែលបានបញ្ជាក់រួចមកហើយ ខ្ញុំបានលើកឡើងមុនពេលដែលសហព្រះរាជអាជ្ញាក្រោកឈរឡើងទី២ លើកទី២។ ការជំទាស់របស់យើង គឺថាឯកសារមួយចំនួននោះមិនត្រូវដាក់ចូលនោះទេ ប្រសិនសាក្សីនោះគឺមកផ្តល់សក្ខីកម្មមិនជាថ្មីទេ ក៏ប៉ុន្តែប្រសិនបើសាក្សីគាត់អត់មកផ្តល់សក្ខីកម្មបញ្ជាក់ទៅលើឯកសារនោះទេ គឺថាយើងមិនឱ្យដាក់ឯកសារនេះបញ្ចូលនេះទេ មិនថាជាសេចក្តីថ្លែងការណ៍ ឬក៏អ្វីនោះឡើយ។

[១៤:១៥:២៩]

ចំពោះប្រភេទឯកសារផ្សេងទៀត ដូចដែលខ្ញុំបានបញ្ជាក់ លិខិត ឯកសារបង្កើតឡើងដោយរដ្ឋាភិបាល ឬក៏ដោយអង្គការមិនមែនរដ្ឋាភិបាល យើងបានបញ្ជាក់នៅក្នុងប្រតិចារឹករួចហើយ ហេតុអ្វីបានជាយើងមិនគួរទទួលយក។ ហើយដើម្បីពង្រីកបន្ថែម គឺឯកសារនៅក្នុងបញ្ជីរបស់យើងនោះ គឺថាវាអាចជាន់គ្នា ហើយយើងក៏បានលើកឡើងជំហររបស់យើងផងដែរ។ ដូច្នេះហើយប្រសិនបើជាន់គ្នាមែននោះ ខ្ញុំសូមអធ្យាស្រ័យដែលបានចំណាយពេលតុលាការ ឬក៏ពេលរបស់ភាគីផ្សេងទៀត។

សូមអរគុណលោកប្រធាន។

[១៤:១៦:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:២៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយសារអង្គជំនុំជម្រះបានស្ដាប់នូវបញ្ហា ដែលលើកឡើងដោយភាគីនានាពាក់ព័ន្ធនឹងការដាក់ឯកសារ និងនីតិវិធី និងបច្ចេកទេសមួយចំនួននៅក្នុងការដាក់ឯកសារ ឬក៏សារណាតបទៅនឹង -- ជំទាស់ទៅនឹងការដាក់ឯកសាររបស់ភាគីម្ខាងទៀត។ ដូច្នេះបញ្ហាមានចំនួនច្រើនដែរ ហើយដើម្បីឲ្យដំណើរការហ្នឹងប្រព្រឹត្តទៅបានល្អនាពេលខាងមុខ អង្គជំនុំជម្រះសម្រេចប្រកាសសម្រាក ៤០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ដោយអង្គជំនុំជម្រះយកពេលវេលានេះសម្រាប់ពិភាក្សាសម្រេចលើរាល់បញ្ហា ដែលអង្គជំនុំជម្រះបានជួបប្រឈមនាពេលអម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:១៨ នាទី ដល់ម៉ោង ១៥:១៦ នាទី)*

[១៥:១៦:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អម្បាញ់មិញនេះ ដោយមានសំណើសុំឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ ឬក៏ណែនាំអំពីនីតិវិធីនៃការដាក់បង្ហាញនូវឯកសារ នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយដើម្បីឲ្យមានលក្ខណៈច្បាស់លាស់ អង្គជំនុំជម្រះបាន ក្រោយពីបានពិភាក្សាគ្នាលើបញ្ហានេះ អង្គជំនុំជម្រះនឹងមានការណែនាំដល់ភាគីដើម្បីសម្រួលលើបញ្ហានេះនាពេលសវនាការលើកឯកសារទៅថ្ងៃមុខ ចំពោះការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ការជំទាស់របស់ភាគី ឬក៏ការឆ្លើយតបទៅនឹងសេចក្ដីជំទាស់ជាដើម។ ហើយអង្គជំនុំជម្រះផ្ដល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបង្ហាញអំពីសេចក្ដីណែនាំរបស់អង្គជំនុំជម្រះលើបញ្ហានេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

[១៥:១៧:៣៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានបញ្ហាចំនួនពីរដែរអង្គជំនុំជម្រះចាំបាច់ត្រូវការផ្តល់ការណែនាំទៅដល់ភាគី។ ចំណុចទាំងពីរនេះគឺរួមមាន៖

ការពិភាក្សាលើភាពអាចទទួលយកបាននៃឯកសារ ហើយក្រៅពីចំណុចនេះ គឺការបង្ហាញឯកសារពាក់ព័ន្ធសំខាន់ៗ។

ការណែនាំរបស់អង្គជំនុំជម្រះសូមលើកឡើងជាបឋម ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាន ហើយបន្ទាប់មក គឺខ្ញុំនឹងលើកឡើងអំពីបញ្ហាឯកសារពាក់ព័ន្ធសំខាន់ៗ។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការិយាល័យព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបានធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ ពាក់ព័ន្ធទៅនឹងការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារ។

អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញផងដែរ ថាក្រុមមេធាវីការពារក្តី អៀង សារី បានឆ្លើយតបដោយផ្ទាល់មាត់ផងដែរ។ ក៏ប៉ុន្តែមេធាវីរបស់លោក អៀង សារី បានយោងអំពីការធ្វើការសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

អង្គជំនុំជម្រះសូមឲ្យលោកមេធាវី កាណាវាស បញ្ជាក់ថា តើអាចធ្វើទៅបានដែរឬទេ ប្រសិនបើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះ គឺយោងទៅលើអ៊ីម៉ែលដែលបានចែកជូននៅក្នុងថ្ងៃនេះ? សូមលោក កាណាវាស បញ្ជាក់។

[១៥:១៩:២៣]

**លោក ម៉ៃខល កាណាវាស៖**

ការពិតទៅ គឺវាយោងទៅលើឧបសម្ព័ន្ធទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងបទបង្ហាញកាលពីម្សិលមិញ។ ហើយជាការពិត សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់យើងនោះ គឺវាពាក់ព័ន្ធទៅនឹងការចែកជូនរបស់យើងកាលពីរសៀលនេះ ក្រោយពីយើងបានពិចារណាទៅលើមតិយោបល់ទាំងឡាយដែលបានលើកឡើងដោយភាគី។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា តើលោកត្រូវការរយៈពេលប៉ុន្មានទៀត ដើម្បីធ្វើការពិនិត្យសម្រេចចុង

ក្រោយដំណើរការបង្ហាញឯកសារនេះ?

[១៥:២០:០០]

**លោក ម៉ៃខល កាណាវាស៖**

ក្រោយពេលស្ដាប់នូវក្នុងរសៀលនេះ នៅពេលនេះយើងកំពុងតែផ្ទៀងផ្ទាត់ហើយ យើងបានគិតថាយើងបានផ្ទៀងផ្ទាត់គ្រប់ហើយ លើកលែងតែយើងខ្វះចំណុចណាខ្លះ។ ហើយយើងគិតថានៅថ្ងៃស្អែកនោះគឺថា យើងនឹងបញ្ចប់។ មានបញ្ហាមួយដែលមិនច្បាស់លាស់ ទី១ គឺថាចៅក្រម ឡាវែន៍ បានបង្ហាញឯកសារមួយទៅកាន់សាក្សី ហើយមានភាគីណាមួយជំទាស់។ ជាការពិតភាគីមិនអាចជំទាស់ទៅនឹងការបង្ហាញឯកសាររបស់ចៅក្រមទៅកាន់សាក្សីនោះទេ ក៏ប៉ុន្តែបញ្ហាចោទថា តើត្រូវមានបញ្ហាចោទអ្វី ប្រសិនបើឯកសារ D នេះផ្លាស់ទៅជាឯកសារ E ហើយយើងព្យាយាមធ្វើការដាក់បញ្ចូលឯកសារនេះ ដូច្នេះចំណុចនេះហើយដែលវាជាពាក់ព័ន្ធទៅនឹងបញ្ហាចោទនៃការដាក់ឯកសារ។ យើងខ្ញុំសង្ឃឹមថា យើងខ្ញុំនឹងទទួលបាននូវការកោសលុបឧបសម្ព័ន្ធផ្សេងៗដែលបានកោសលុបព័ត៌មានមួយចំនួន។

[១៥:២១:០០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំគិតថាវាជាចំណុចមួយដែលលោកបានលើកឡើងថា លោកនឹងជំទាស់ទៅលើឯកសារមួយចំនួន ហើយសុំឲ្យលោកលើកឡើងយោបល់ជាក់លាក់ ហើយអង្គជំនុំជម្រះឆ្លៀតយកឱកាសនេះធ្វើការថ្លែងអំណរគុណលោកចំពោះពេលវេលា ដែលលោកបានចំណាយក្នុងការរៀបចំសារណាជាលាយលក្ខណ៍អក្សររបស់លោក ដើម្បីយកមកធ្វើការឆ្លើយតបដោយផ្ទាល់មាត់ និងឆ្លើយតបទៅការលើកឡើងរបស់ភាគី។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ លោកស្រីចៅក្រម។ តាមពិតខ្ញុំមិនមែនជំទាស់ទៅលើឯកសារដែលបានដាក់នោះទេ។ មេធាវីក្រុម ខៀវ សំផន នោះបានដាក់សេចក្ដីសន្និដ្ឋានថា តើអ្វីខ្លះអាចជាឯកសារអាចដាក់បាន។ នៅពេលដែលបង្ហាញដោយភាគី ឬក៏ដោយចៅក្រមណាមួយទៅដល់សាក្សីនោះ តើយើងសន្មតថាឯកសារ ឬក៏ផ្នែកដែលបានបញ្ជាំងជូនសាក្សីនោះទទួលយកហើយ ឬក៏យ៉ាងម៉េច? ឬក៏ភាគីចាំបាច់ត្រូវការលើកសំណើសុំទទួលស្គាល់ឯកសារនេះទៀត? ប្រសិនបើចៅក្រមជាអ្នកបង្ហាញឯកសារ យើង

សន្មតថា ចៅក្រមចង់ដាក់ឯកសារហ្នឹងចូលទៅក្នុងសំណុំរឿង។ ហេតុដូច្នេះប្រសិនបើអនុញ្ញាតនោះ ខ្ញុំមិនមែនថាព្យាយាមតវ៉ានៅពេល -- នៅទីនេះនោះទេ។

[១៥:២២:២១]

នៅតុលាការ -- នៅសាលាក្តី អាយ.ស៊ី.ធី.វ៉ាយ នៅពេលដែលបង្ហាញឯកសារកាន់ទៅសាក្សី នោះគឺថាមិនមែនឯកសារនោះទទួលយកទាំងស្រុងនោះទេ យើងត្រូវតែដាក់ពាក្យសុំទទួលយកឯកសារនេះទៀត។ ជាធម្មតាផ្នែកដែល នៅក្នុងឯកសារដែលបានបញ្ចាំងនោះ បើសិនបើយើងចង់ដាក់បញ្ចូលនោះ យើងត្រូវតែដាក់ពាក្យថា ហេតុអ្វីបានជាផ្នែកមួយចំនួនបានបង្ហាញសាក្សី ហើយផ្នែកផ្សេងទៀតមិនបានបង្ហាញសាក្សី? យើងត្រូវតែពន្យល់។ ដូច្នេះហើយវាត្រូវតែមានការបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយអង្គជំនុំជម្រះត្រូវបញ្ជាក់ទៅលើចំណុចហ្នឹងជូនដំណឹងឲ្យយើងខ្ញុំបានដឹងផងដែរ ដើម្បីនៅក្នុងពេលអនាគតនេះយើងត្រូវដោះស្រាយនិងធ្វើយ៉ាងម៉េចចំពោះឯកសារនេះ។

ខ្ញុំមិនមែន ខ្ញុំមិនចង់ធ្វើការក្រោកឈរឡើងដើម្បីជំទាស់ទៅនឹងការបង្ហាញឯកសាររបស់ចៅក្រមណាមួយ ដូចជាចៅក្រម ឡាវ៉ែន៍ នោះទេ។ ខ្ញុំដឹងហើយថាចៅក្រមមានសិទ្ធិសួរសំណួរណាក៏បានដែរ ក៏ប៉ុន្តែខ្ញុំមានកាតព្វកិច្ច ហើយខ្ញុំមានបុព្វសិទ្ធិក្នុងការជំទាស់ទៅលើឯកសារមួយចំនួន។

ហើយចៅក្រមត្រូវដឹងអំពីអង្គហេតុមួយចំនួនដែលថា វាជាកម្រិតចំពោះសាក្សី។ ហើយពេលខ្លះទៅវា -- សំណួរមួយចំនួនវាអាចមានលក្ខណៈមិនសមរម្យផងដែរ។ ខ្ញុំនិយាយនេះក្នុងនាមខ្ញុំផ្ទាល់ទេលោក លោកស្រីចៅក្រម។

[១៥:២៣:៣១]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំយល់ ខ្ញុំយល់អំពីគំនិតរបស់លោកនៅទីនេះ ក៏ប៉ុន្តែនៅពេលនេះយើងនិយាយអំពីការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារ។ ប្រសិនមិនមានការជំទាស់ណាមួយទៅលើឯកសារបង្ហាញដោយចៅក្រមនោះ នោះគឺថាយើងនឹងបញ្ចប់បញ្ហានេះរួចរាល់នេះតែម្តង។ ប៉ុន្តែការឆ្លើយតបវាពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងមួយទៀត។ ហើយខ្ញុំ យ៉ាងណាក៏ដោយគិតថាអ្វីដែលខ្ញុំបានបំភ្លឺនេះបានមកឲ្យលោកយល់ច្បាស់លាស់ហើយ។

**លោក ម៉ៃខល កាណាវាស៖**

បាទ ខ្ញុំយល់ច្បាស់លាស់ហើយ លោកស្រីចៅក្រម។

[១៥:២៤:០៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោក កាណាវាស គឺលោកមានពេលរហូតដល់ថ្ងៃស្អែកដើម្បីផ្ទៀងផ្ទាត់ និងពិនិត្យសម្រេចចុងក្រោយទៅលើឯកសាររបស់លោក។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញ យើងខ្ញុំថ្លែងអំណរគុណចំពោះកិច្ចប្រឹងប្រែងរបស់លោកដែលបានធ្វើឡើងនេះ។ បញ្ហាបន្ទាប់ពាក់ព័ន្ធទៅនឹងការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារ គឺមានដូចតទៅ "ខៀវ សំផន ក្រុមមេធាវីខៀវ សំផន និង នួន ជា ទាំងពីរក្រុមបានបញ្ជាក់ថា ពួកគាត់ទាំងពីរក្រុមមិនទាន់ត្រៀមខ្លួនរួចហើយក្នុងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងពេលសវនាការនេះ ស្ដីអំពីការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារណាមួយនោះទេ"។ ហើយយើងក៏កត់សម្គាល់ឃើញផងដែរថា កូនក្ដីរបស់គាត់នីមួយៗបានចូលមន្ទីរពេទ្យសម្រាកក្នុងមន្ទីរពេទ្យកាលសប្ដាហ៍មុន ហើយបន្ថែមពីលើនេះ អង្គជំនុំជម្រះបានកំណត់រយៈពេលឲ្យសរសេរការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារទាំងអស់នេះ។ ក៏ប៉ុន្តែ វានៅមានបញ្ហាមួយទៀត តាំងពីខែធ្នូ កាលពីឆ្នាំមុន។ ដូច្នេះហើយអង្គជំនុំជម្រះសូមសម្រេចថា ក្រុមមេធាវី ខៀវ សំផន និង នួន ជា អាចដាក់ការជំទាស់ណាមួយដែលខ្លួនមានទៅនឹងភាពអាចទទួលយកឯកសារឲ្យបានត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣។ ភាគីផ្សេងទៀតមានឱកាសឆ្លើយតបត្រឹមថ្ងៃទី២៦ ខែកុម្ភៈ -- សូមកែតម្រូវ ភាគីផ្សេងទៀតមានសិទ្ធិក្នុងការដាក់ការឆ្លើយតបត្រឹមថ្ងៃ២២ ខែមករា។ ហើយអង្គជំនុំជម្រះនៅពេលក្រោយមក គឺថានឹងចេញសេចក្ដីសម្រេចលើបញ្ហាទាំងអស់នេះ។ ដូច្នេះយើងនឹងធ្វើការសម្រេច។ បាទ សូមកែតម្រូវ គឺខែកុម្ភៈ។

[១៥:២៦:១០]

ក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន គឺដាក់ការជំទាស់របស់ខ្លួនត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ហើយភាគីផ្សេងទៀតមានសិទ្ធិឆ្លើយតបត្រឹមថ្ងៃទី២៦ ខែកុម្ភៈ -- ២២ សូមកែតម្រូវលោកប្រធាន។

នៅពេលនេះគឺយើងលើកឡើងអំពីប្រធានបទមួយទៀតដោយឡែក ពាក់ព័ន្ធទៅនឹងឯកសារសំខាន់ -- ឯកសារពាក់ព័ន្ធសំខាន់ៗ។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីអំពីគោលបំណងនៃការ -- នៃសវនាការ ដែលបានបញ្ជាក់ថា រៀបចំឡើងសម្រាប់បញ្ហាឯកសារ ហើយជាពិសេសលើឯកសារទាំងឡាយណាដែលវាពាក់ព័ន្ធសំខាន់ទៅនឹងផ្នែកនៃការជំនុំជម្រះសវនាការយើង។

ជាបឋមភាគីមានឱកាស គូសបញ្ជាក់ឯកសារណាមួយដែលខ្លួនយល់ឃើញថាមានសារៈសំខាន់

ចំពោះរឿងក្តីរបស់ខ្លួន។ ហើយចំណុចទី២ គោលបំណងទី២នេះ ការរៀបចំសវនាការនេះឡើង គឺដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដូចដែលបានលើកឡើងពីមុននេះ។

សវនាការនេះគឺមានបំណងឲ្យបង្ហាញឯកសារ និងដើម្បីធានាអំពីវិធីក្នុងការពិនិត្យមើលឯកសារភស្តុតាងទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងការជំនុំជម្រះ។ បានន័យថា វាជាឱកាសផ្តល់ឲ្យសាធារណជនយល់អំពីសេចក្តីសង្ខេបចំពោះឯកសារពាក់ព័ន្ធសំខាន់ៗ។ ហើយបន្ថែមពីនេះ សវនាការនេះដើម្បីផ្តល់ឱកាសទៅដល់ភាគីដែលខ្លួនចង់បាន ឲ្យភាគីនេះបង្ហាញអំពីឯកសារពាក់ព័ន្ធសំខាន់ៗរបស់ខ្លួន ជាពិសេសឯកសារពាក់ព័ន្ធសំខាន់ៗរបស់ភាគីទៅនឹងផ្នែកនៃការជំនុំជម្រះនីមួយៗ។

[១៥:២៨:១៧]

ឯកសារដែលបង្ហាញដោយភាគីនៅក្នុងសវនាការនេះ គឺជនជាប់ចោទក៏មានសិទ្ធិផ្តល់យោបល់ទៅលើឯកសារទាំងអស់នោះដែរ ប្រសិនបើជនជាប់ចោទជ្រើសរើសផ្តល់យោបល់។ ឧទាហរណ៍ដូចដែលអនុស្សរណៈ E3/70 ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះបានបញ្ជាក់ហើយថា ជនជាប់ចោទបានបដិសេធមិនធ្វើការឆ្លើយតបទៅលើឯកសារក្នុងពេលសវនាការ។ ដូច្នេះបានន័យថា ជនជាប់ចោទអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដោយសារតែយើងដឹងហើយថា ការពិភាក្សាទៅលើឯកសារទាំងអស់នេះ គឺនឹងមិនអនុញ្ញាតឲ្យលើកឯកសារណាមួយនោះទេ ប្រសិនបើមិនមានការសម្រេចទៅលើភាពអាចទទួលយកបាននៃឯកសារជាក់លាក់នោះ។

អង្គជំនុំជម្រះមិនដែលធ្លាប់រារាំងក្រុមមេធាវីការពារក្តី ឬក៏ជនជាប់ចោទនិយាយអំពីភាពពាក់ព័ន្ធ និងតម្លៃនៃភស្តុតាងក្នុងឯកសារទាំងអស់នោះទេ។ យើងឃើញថានៅក្នុងករណីមួយចំនួន ឧទាហរណ៍ថា CE2 ឯកសារ E233 កថាខណ្ឌ៣ ឱកាសនោះគឺរួមទាំងឱកាសផ្តល់ទៅដល់ជនជាប់ចោទផ្តល់យោបល់ទៅលើឯកសារទាំងឡាយណា ដែលបានដាក់បង្ហាញ ឬក៏ឯកសារទាំងឡាយណាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងពេលសវនាការ។ ដូច្នេះនេះគឺនិយាយជារួមអំពីគោលបំណងទូទៅ អំពីសវនាការបង្ហាញឯកសារពាក់ព័ន្ធសំខាន់ៗ។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការិយាល័យសហព្រះរាជអាជ្ញាបានចាប់ផ្តើមដំណើរការបង្ហាញឯកសារនេះរួចមកហើយ ហើយសហមេធាវីនាំមុខបានបញ្ជាក់ហើយថាខ្លួននឹងធ្វើបទបង្ហាញឯកសាររបស់ខ្លួនក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីបញ្ជាក់បំភ្លឺអំពីនីតិវិធីពាក់ព័ន្ធទៅនឹងការបង្ហាញ

ឯកសារពាក់ព័ន្ធសំខាន់ៗចាប់ពីពេលនេះតទៅ។ វាទំនងជាបង្ហាញថា វាទំនងជាភាគីមួយចំនួននោះអាចមានលទ្ធភាពក្នុងការបង្ហាញឯកសារសំខាន់ៗ ហើយយើងខ្ញុំគិតថាឲ្យខាងសហព្រះរាជអាជ្ញាបន្តការបង្ហាញឯកសារដែលពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដំណាក់កាលទី១ និងឯកសារពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ។ បន្ទាប់មក គឺត្រូវបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដំណាក់កាលទី២។

[១៥:៣១:២១]

បន្ទាប់ពីបទបង្ហាញនេះហើយ សហមេធាវីនាំមុខនឹងស្នើសុំឲ្យធ្វើការបង្ហាញបំពេញបន្ថែម ឬក៏បង្ហាញឯកសារលើប្រធានបទដែលខ្លួនចង់លើកឡើង។ ដូច្នេះពាក់ព័ន្ធទៅនឹងចំណុចនេះ វានៅសល់មានឯកសារពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម និងតួនាទីរបស់ជនជាប់ចោទមួយទៀត។ លោកប្រធានខ្ញុំគិតថា ប្រធានបទទាំងពីរនេះក៏ឲ្យសហព្រះរាជអាជ្ញានោះបង្ហាញផងដែរឯកសារពាក់ព័ន្ធតួនាទីជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម ប្រសិនបើសហព្រះរាជអាជ្ញាចង់ធ្វើដូច្នេះ។ ហើយសហមេធាវីនាំមុខអាចលើកឡើងផងដែរ ហើយភាគីផ្សេងទៀតអាចបង្ហាញយោបល់។

អង្គជំនុំជម្រះសង្ឃឹមថា ភាគីទាំងឡាយនឹងត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ហាញឯកសារពាក់ព័ន្ធសំខាន់ៗ ហើយធ្វើបទបង្ហាញទៅតាមអ្វីដែលខ្លួនយល់ឃើញថាសមស្រប។ ដូច្នេះ សហព្រះរាជអាជ្ញាខ្ញុំចង់សួរថា តើលោកត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ហាញអំពីឯកសារពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម និងតួនាទីរបស់ជនជាប់ចោទ ហើយនិងឯកសារពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដំណាក់កាលទី១ និងទួលពោធិ៍ជ្រៃដែរឬទេ?

[១៥:៣២:៤៤]

**លោក ឃីត វេយ្យ័ន្ត៖**

ខ្ញុំសូមឆ្លើយថា យើងខ្ញុំមិនទាន់ត្រៀមខ្លួនរួចនោះទេ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ជំហរថា ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយសំណើរបស់យើងខ្ញុំបានដាក់កាលពីសប្តាហ៍មុន។ សំណើបានស្នើមកខាងសហព្រះរាជអាជ្ញាកាលពីសប្តាហ៍មុនពាក់ព័ន្ធទៅនឹងការតម្រូវឲ្យបង្ហាញឯកសារទាក់ទងទៅនឹងរចនាសម្ព័ន្ធកងទ័ព ហើយយើងដឹងហើយថា ឯកសារពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីលំនៅដំណាក់កាលទី១ និងទួលពោធិ៍ជ្រៃ និងការផ្លាស់ប្តូរលំនៅដំណាក់កាលទី២ និងត្រូវក៏បង្ហាញផងដែរ។ ខ្ញុំសូមពន្យល់ថាតាមសំណើឲ្យយើងខ្ញុំរៀបចំការបង្ហាញឯកសារទាំងអស់នេះ សហព្រះរាជអាជ្ញាគឺបានបែងចែក

ជាក្រុមដើម្បីធ្វើការបង្ហាញឯកសារនៅក្នុងរសៀលនេះ។ ហើយដែលថា ក្រុមសហព្រះរាជអាជ្ញារបស់យើងនឹងធ្វើការបង្ហាញឯកសារទៅតាមក្រុមនីមួយៗ។ ការងារនេះគឺសំខាន់ ហើយយើងនឹងត្រូវធ្វើទៅតាមរយៈពេលដែលបានកំណត់រួម។ ហើយយើងខ្ញុំបានធ្វើការយ៉ាងច្រើន រួមទាំងការងារនៅថ្ងៃសៅរ៍ និងអាទិត្យផងដែរ។

[១៥:៣៣:៥៧]

ខ្ញុំសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាគឺយល់យ៉ាងច្បាស់អំពីពេលវេលារបស់អង្គជំនុំជម្រះ យើងក៏ដឹងអំពីចាំបាច់ថាត្រូវប្រើប្រាស់ពេលវេលារបស់អង្គសវនាការឲ្យបានប្រសិទ្ធភាពក្នុងការបង្ហាញឯកសារជូនអង្គជំនុំជម្រះ។ យើងខ្ញុំបានពិភាក្សាប្រធានបទទាំងអស់នេះ ដែលលោកស្រីចៅក្រមខាតវ៉ាយថ៍ បានលើកឡើងនៅក្នុង អ្វ.ស៊ី.ភី ការិយាល័យសហព្រះរាជអាជ្ញាកាលពីប៉ុន្មានថ្ងៃមុន។ យើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំមិនអាចបង្ហាញឯកសារទាំងអស់ក្នុងរយៈពេលកម្រិតមួយដូចដែលអង្គជំនុំជម្រះបានផ្តល់ជូននោះទេ។ ការត្រៀមខ្លួនក្នុងការបង្ហាញឯកសារទាំងអស់នោះ គឺថាយើងខ្ញុំនឹងត្រៀមខ្លួនជាស្រេច ក៏ប៉ុន្តែយើងខ្ញុំសូមឲ្យមានការផ្តល់អនុគ្រោះបន្តិចបន្តួចទៅនឹងពេលវេលា។ ចំពោះឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ គឺថាយើងខ្ញុំសូមលើកឡើងថា ការរៀបចំ គឺថាយើងបានរៀបចំរួចមកហើយ យើងកំពុងតែត្រៀមរៀបចំ។ ខ្ញុំអាចជម្រាបអង្គជំនុំជម្រះផងដែរថា សហព្រះរាជអាជ្ញានីមួយៗត្រូវបានទទួលភារៈទៅលើផ្នែកនៃឯកសារដែលពាក់ព័ន្ធ។ ពួកគាត់កំពុងតែចាប់ផ្តើមរៀបចំការបង្ហាញរបស់ពួកគាត់ហើយ ក៏ប៉ុន្តែយើងខ្ញុំស្នើសុំពេលវេលាបន្ថែម។ ដូច្នេះហើយពេលវេលាដែលខ្ញុំសូមស្នើឡើងនោះ ទោះបីជាខ្ញុំមិនទាន់បានពិភាក្សាជាមួយនឹងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិក៏ដោយ ខ្ញុំក៏ដឹងថាខាងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនោះគឺក៏ពួកគាត់ចង់សុំពេលវេលាបន្ថែមរហូតដល់ព្រឹកថ្ងៃស្អែក។ ដូច្នេះជាសង្ខេបមក គឺយើងមិនទាន់បានត្រៀមខ្លួនរួចជាស្រេចនោះទេ យើងកំពុងធ្វើការងារលើបញ្ហានេះ។ យើងខ្ញុំស្នើសុំពេលវេលាបន្ថែមដើម្បីត្រៀមរៀបចំការបង្ហាញឯកសារទាំងអស់នេះដើម្បីឲ្យអង្គជំនុំជម្រះនោះទទួលបានការបង្ហាញ បទបង្ហាញដ៏មានលក្ខណៈលម្អិតជាក់លាក់ច្បាស់លាស់។ សូមអរគុណ។

[១៥:៣៦:០៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណចំពោះការចង្អុលបង្ហាញនេះ។ នេះហើយគឺជាគោលដៅដែលយើងធ្វើការចោទសួរ

ទៅខាងក្រុមរបស់លោក។ អង្គជំនុំជម្រះនឹងរង់ចាំនូវការបញ្ជាក់របស់ខាងលោកទាក់ទងទៅនឹងពេលវេលាដែលក្រុមលោកត្រូវការ គឺអំពីពេលវេលាដែលអស់លោកត្រូវការដើម្បីរៀបចំនូវបទបង្ហាញនេះ។ ហើយយើងនឹងបន្តទៅមុខទៀត។ ឥឡូវនេះ អ្វីដែលយើងមិនទាន់បានបំពេញគឺយើងត្រូវធ្វើការថ្លែងអំណរគុណផងដែរដល់ខាងព្រះរាជអាជ្ញាដែលបានធ្វើនូវការបង្ហាញ ក៏ដូចជាការរៀបចំយ៉ាងល្អទាក់ទងទៅនឹងការជំទាស់ទៅលើឯកសារ ក៏ដូចជាការធ្វើបទបង្ហាញយ៉ាងល្អទាក់ទងទៅនឹងឯកសារគន្លឹះ។ យើងសូមថ្លែងអំណរគុណដែលក្រុមអស់លោកបានបំពេញការងារ ហើយយើងក៏អគុណដល់ក្រុម អៀង សារី ផងដែរ។ នេះគឺជាអ្វីដែលក្រុមរបស់លោកបានធ្វើ។ ក្នុងពេលឥឡូវនេះយើងនឹងនិយាយអំពីការធ្វើបទបង្ហាញទាក់ទងទៅនឹងឯកសារគន្លឹះស្ដីពីការជម្លៀសដំណាក់កាលទី១ ទួលពោធិជ្រៃ និងការជម្លៀសដំណាក់កាលទី២ បន្ទាប់មកខាងសហព្រះរាជអាជ្ញា តំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងបន្ត។ ហើយនៅពេលពីរបីថ្ងៃក្រោយមកទៀត នៅពេលដែលក្រុមអស់លោកបានបញ្ជាក់ច្បាស់ថាតើលោកត្រូវការពេលវេលាប៉ុន្មាននោះ យើងនឹងផ្ដល់នូវពេលវេលាដើម្បីឲ្យអស់លោកធ្វើការបង្ហាញនូវប្រធានបទដែលនៅសល់ ហើយខ្ញុំក៏សូមជម្រាបដល់ក្រុមមេធាវីការពារក្ដីផងដែរថា មានការងារជាច្រើនដែលនៅរង់ចាំ។ ហើយយើងសង្ឃឹមថា ក្រុមមេធាវីការពារក្ដីនឹងធ្វើការបង្ហាញទាក់ទងទៅនឹងឯកសារគន្លឹះរបស់ខ្លួន ហើយប្រហែលជាអាចនឹងមានការជូនដំណឹងខ្លី ឬក៏សង្ខេបទាក់ទងទៅនឹងបញ្ហាសុខភាព ឬក៏បញ្ហានានា។

លោកប្រធាន ខ្ញុំសង្ឃឹមថា ខ្ញុំបាននិយាយអ្វីដែលយើងបានពិភាក្សាគ្នាកាលពីរសៀលនេះហើយ។ តើខ្ញុំបាននិយាយសព្វគ្រប់ចំណុចទាំងអស់ដែរឬទេលោកប្រធាន?

[១៥:៣៨:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អគុណលោកស្រីចៅក្រម។

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បំភ្លឺចំណុចមួយនៅក្នុងចម្លើយរបស់ខ្ញុំក្នុងករណីដែលថាមិនច្បាស់លាស់ ខ្ញុំកត់សម្គាល់លើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅថ្ងៃនេះ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ការច្របូកច្របល់មួយដែលខាងការពារក្ដីមិនយល់ច្បាស់នៅក្នុងការយល់មិនច្បាស់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះ ដែលខ្ញុំបានលើកឡើងព្រឹកមិញ ហើយលោកស្រីចៅក្រម ខាតវ៉ាយថ៍ ក៏និយាយទៀតដែរ

អម្បាញ់មិញ គឺថានៅកថាខណ្ឌទី៤ នៃអនុស្សរណៈ E170 ដែលយើងមានភាពច្រឡូលច្របល់ ដែលថាការប្រជុំយើងនោះ សវនាការយើងនេះបានមានចង្អុលបង្ហាញនៅកថាខណ្ឌទី៤នោះ គឺថាសវនាការនេះមិនទាន់ទងទៅនឹងការភាពទទួលបាននៃឯកសារនោះទេ ពីព្រោះថាយើងមិនត្រូវបាន -- មិនបានត្រៀមអំពីចម្លើយទាំងអស់ទេ។ អ៊ីចឹងដោយសារយើងយល់ខុសអ៊ីចឹងហើយបានយើងគិតថា ដោយយើងយល់កថាខណ្ឌទី៤នេះខុសអ៊ីចឹងហើយ បានយើងមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់។ ហើយសូមទោសដែលខ្ញុំនិយាយលឿនយ៉ាងដូច្នេះ។

ខ្ញុំសូមនិយាយម្តងទៀត គឺថានៅកថាខណ្ឌទី៤ នៃអនុស្សរណៈ E170 សវនាការនេះមិនទាក់ទងទៅនឹងភាពទទួលយកបាននៃឯកសារក្នុងការបង្ហាញជូនអង្គជំនុំជម្រះនោះទេ ហើយមិនបានគ្រោងឲ្យភាគឆ្លើយតបទៅនឹងឯកសារដែលយើងដាក់ចំពោះមុខអង្គជំនុំជម្រះនោះទេ។ អ៊ីចឹងហើយបានជាយើងមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ ហើយឥឡូវខ្ញុំសូមរំឭកផងដែរថា យើងយល់ច្បាស់ហើយថាជនជាប់ចោទទាំងអស់អាចមានសិទ្ធិធ្វើការកត់សម្គាល់ រួមទាំងលោក ខៀវ សំផន ផងដែរ។ ក៏ប៉ុន្តែសូមអភ័យទោសម្តងទៀតគឺថា កាលយើងអានអនុស្សរណៈនេះទៅឃើញថាយើងយល់ហាក់ដូចជាខុសពីអង្គជំនុំជម្រះ។

[១៥:៤០:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤០:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដែលប្រើប្រាស់ជាភាសាបារាំង ហើយមេធាវីការពារក្តីដែលមានចម្ងល់អម្បាញ់មិញនេះក៏លោកស្រីជាជនជាតិបារាំងដែរប្រើភាសាបារាំងដូចគ្នា ហើយនិយាយឲ្យបានច្បាស់លាស់លើបញ្ហានេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:៤០:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាមិនច្បាស់ថា ចង់ឆ្លើយតបនោះទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងនោះគឺថា តើគោលជំហររបស់អង្គជំនុំជម្រះនេះយល់ច្បាស់ហើយឬនៅ ភាគីយល់ច្បាស់ហើយឬនៅ

ជាពិសេសគឺថាក្រុមការពារក្ដីលោក ខៀវ សំផន នេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ឥឡូវខ្ញុំយល់ច្បាស់ហើយ គឺថាវាខុសពីអ្វីដែលយើងយល់នៅក្នុងអនុស្សរណៈហ្នឹង ពីព្រោះថាគោលជំហររបស់យើងនោះ ពីមុនមកគឺថាយើងយល់ទៅតាមអនុស្សរណៈនេះ។ អ៊ីចឹងហើយបានយើងសុំលទ្ធភាពឆ្លើយតបទៅ -- ឆ្លើយតបទៅនឹងសវនាការពីមុនមកនោះទាក់ទងនឹងការបង្ហាញឯកសារ។ ហ្នឹងជារឿងធម្មតាទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំគ្រាន់តែសុំរំឭកផងដែរថា នៅក្នុងអនុស្សរណៈហ្នឹង នៅពេលដែលឯកសារ ភាគីបង្ហាញឯកសារមួយនៅក្នុងសវនាការនិយាយពីឯកសារនេះ បើសិនជាភាគីចង់ធ្វើការកត់សម្គាល់អីនោះ អាចធ្វើការកត់សម្គាល់បាន។ ហើយមាននេះ មានការបញ្ជាក់ -- បាទ ជនជាប់ចោទមានសិទ្ធិធ្វើការកត់សម្គាល់បាន ហើយមានការបញ្ជាក់យ៉ាងច្បាស់។

[១៥:៤២:១៩]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនចង់និយាយពន្យារទេ ព្រោះថាគោលជំហររបស់យើងច្បាស់លាស់ហើយ។ ខ្ញុំសុំទោសដែលខ្ញុំនិយាយលឿន។ គោលជំហររបស់យើងហ្នឹងច្បាស់លាស់ហើយ គឺថាខ្ញុំហាក់ដូចជាយល់ថាសហមេធាវី វែកគែន នោះគាត់បានថាជម្រាបជូនហើយ ថាគាត់មិនចូលរួមនិយាយក្នុងសវនាការបែបហ្នឹងទេ។ ដូច្នេះខ្ញុំសូមរំឭកឡើងម្ដងទៀត ព្រោះថាៗមានជនជាប់ចោទ ដូច្នេះត្រូវតែគិតពីជនជាប់ចោទហើយនិងគិតពីកថាខណ្ឌនេះផងដែរ គឺថាជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យធ្វើការកត់សម្គាល់។ គឺថាកថាខណ្ឌទី៤ នៃអនុស្សរណៈ E170 ហ្នឹងឯង។

[១៥:៤៣:១៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៣:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវហ្នឹងគឺសល់ពេលវេលាតិចតួច គឺពេលវេលាសមល្មមសម្រាកហើយសម្រាប់កិច្ចដំណើរការសម្រាប់ថ្ងៃនេះ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹម

នេះហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ សូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានពីចម្ងាយនៅព្រឹកស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៤៤ នាទី)*